ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# អត្ថប្រយោជន៍ដែលទទួលបានពីក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជា រី"

# THE BENEFITS PROVIDED BY CAMBODIAN REINSURANCE COMPANY "CAMBODIA RE"

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# អត្ថប្រយោជន៍ដែលទទួលបានពីក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជា រី"

# THE BENEFITS PROVIDED BY CAMBODIAN REINSURANCE COMPANY "CAMBODIA RE"

លោកគ្រូណែនាំ៖ ប៊ុន មករា

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី២២**
**ប្រធានបទៈ អត្ថប្រយោជន៍ដែលទទួលបានពីក្រុមហ៊ុនធានារ៉ាប់រងបន្ត**

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត មាស សំណាង

លោកគ្រូណែនាំ

ប៊ុន មករា

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត យ៉ែម សុខហៀក

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

ប្រធានគណៈកម្មការវាយតម្លៃ និងជានាយក
មជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

អនុប្រធានគណៈកម្មការវាយតម្លៃ និងជានាយករង
មជ្ឈមណ្ឌលស្រាវជ្រាវ

បេក្ខបណ្ឌិត ស្រេង ផល្លា

**សាកលវិទ្យាធិការ**

**បណ្ឌិត ហេង វ៉ាន់ដា**

សាកលវិទ្យាធិការរងអចិន្ត្រៃយ៍

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រជំនាញគណនេយ្យនៅសាកលវិទ្យាល័យវ៉ាន់ដា អស់រយៈពេល ៤ឆ្នាំសិក្សារួចមក ក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើនដែលពាក់ព័ន្ធនឹងមុខវិជ្ជាគណនេយ្យ ជាផ្សារបច្ចុប្បន្ន ក្នុងនោះមិនថា ជាស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តីសុទ្ធតែត្រូវអនុវត្តន៍កិច្ចការគណនេយ្យដូចគ្នា។ ដោយឡែក ដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែមានគុណភាពខ្ពស់ និងលទ្ធផលល្អសាកលវិទ្យាល័យវ៉ាន់ដាបានបញ្ចូលនូវមុខជំនាញសំខាន់ៗ ដែលពាក់ព័ន្ធនឹងការងារគណនេយ្យតាមកម្មវិធីសិក្សាក្នុងឆ្នាំសិក្សាទី១រហូតដល់ឆ្នាំសិក្សាទី៤។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិតឱ្យបានយល់ច្បាស់ពីការអនុវត្តការងារគណនេយ្យ ពីការចាប់ផ្តើមរៀបចំផែនការ ការអនុវត្ត ការបញ្ចប់ និងត្រួតពិនិត្យ វាយតម្លៃ ព្រមទាំងផ្តល់ជាអនុសាសន៍នៅក្នុងការងារគណនេយ្យ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រង នៅក្នុងស្ថាប័នខ្លួន ក្នុងន័យឆ្លើយតបឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញ។ ដោយក្រុមយើងខ្ញុំសង្កេតឃើញថា កិច្ចការងារមួយនេះមានសារៈសំខាន់ខ្លាំងណាស់ស្របពេលនៃការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្របានឈានមកដល់ ទើបក្រុមយើងខ្ញុំសម្រេចចិត្តថាជ្រើសរើសយកនូវប្រធានបទមួយស្តីពី **"អត្ថប្រយោជន៍ដែលទទួលបានពីក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា កម្ពុជា រី"** យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងក្នុងគោលបំណងឱ្យអ្នកស្រាវជ្រាវទាំងអស់ឱ្យយល់កាន់តែស៊ីជម្រៅអំពីការរៀបចំសារណា និងអត្ថប្រយោជន៍ដែលទទួលបានពីក្រុមហ៊ុនធានារ៉ាប់រងបន្ត។ ក្រុមយើងខ្ញុំសង្ឃឹមថាការរៀបចំសារណាមួយនេះឡើងនឹងបានចូលរួមចំណែកមួយក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដទៃទៀតដែលមានគោលបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំ សូមមេត្តាខន្តីអភ័យទោសពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអានទាំងអស់នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនានៅក្នុងសារណានេះ ហើយក្រុមយើងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធក្រុម



ហ៊ិន សុភា

ID: B22/1741



លាង សុវណ្ណមុនីរ័ត្ន

ID: B22/384



ប៊ិត ភេត្រា

ID: B22/2295



ធី ស្រីពេជ្រ

ID: B22/826



ហ៊ូ ស៊ីណាត

ID: B22/279

# សេចក្តីថ្លែងអំណរគុណ

ក្រុមយើងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យវ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២២ ជំនាញគណនេយ្យ

**សូមសម្តែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្ត ដល់ក្រុមយើងខ្ញុំក្នុងការសិក្សារៀនសូត្រ ដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមយើងខ្ញុំសូមសម្តែងនូវការគោរព និងកត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុតដល់អ្នកមានគុណដែលបានផ្តល់កំណើតដល់ខ្ញុំបាទ នាងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់បណ្ឌាសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ទាំងអស់ដែលបានបណ្តុះបណ្តាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសម្តែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅដល់ឯកឧត្តមបណ្ឌិត**ហេង វ៉ាន់ដា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យវ៉ាន់ដាដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាលព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះលោកគ្រូ **ម៉ុន មករា** ជាគ្រូណែនាំ ដោយបានជួយជ្រោមជ្រែងបង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។

សូមគោរពថ្លែងអំណរគុណដល់សាស្ត្រាចារ្យ និងបុគ្គលិកនៃសាកលវិទ្យាល័យវ៉ាន់ដាទាំងអស់ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំរហូតដល់ធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើឱ្យជួបតែពុទ្ធពរបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អំណះអំណាង

ក្រុមយើងខ្ញុំ ជានិស្សិតបរិញ្ញាបត្រ ជំនាញគណនេយ្យ នៃសាកលវិទ្យាល័យវ៉ាន់ដា ជំនាន់ទី២២៖

សូមធានាអះអាងថា ខ្លឹមសារសារណាក្រោមប្រធានបទស្តីអំពី "អត្ថប្រយោជន៍ដែលទទួលបានពីក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជា រី" នេះគឺពិតជាស្នាដៃមួយរបស់ក្រុមនាងខ្ញុំដោយគ្មានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលដែលទាក់ទងទៅនឹងការស្រាវជ្រាវ ដែលបានលើកឡើងនេះ ជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃ.ពុធ..៨កើត. ខែ.កត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩

ថ្ងៃទី.២៩. ខែតុលា ឆ្នាំ២០២៥

**ហត្ថលេខាតំណាងក្រុម**



ហ៊ិន សុភា

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

យោងតាមការសង្កេតឃើញថា មានការរីកចម្រើនខ្លាំងលើវិស័យធានារ៉ាប់រង ទើបធ្វើឱ្យពួកយើងសម្រេចចិត្តធ្វើការស្រាវជ្រាវលើប្រធានបទ អត្ថប្រយោជន៍ដែលទទួលបានពីក្រុមហ៊ុនធានារ៉ាប់រងបន្ត ហើយនៅក្នុងការស្រាវជ្រាវនេះផងដែរ មានគោលបំណងមួយចំនួនដូចជាការសិក្សាលើ សេវាកម្មធានារ៉ាប់រងបន្ត និងការដឹកនាំផ្សេងៗទៀតរបស់ក្រុមហ៊ុនកម្ពុជារី ដើម្បីឱ្យកាន់តែច្បាស់ និងងាយស្រួលក្នុងការសន្និដ្ឋាន  និងផ្តល់អនុសាសន៍។

ក្រោយពីការសិក្សាយ៉ាងយកចិត្តទុកដាក់ទៅលើប្រធានបទមួយនេះរួចមក យើងខ្ញុំទទួលបាននូវការយល់ដឹងកាន់តែច្បាស់អំពីប្រវត្តិនៃការកកើតនៃវិស័យធានារ៉ាប់រងដំបូងបង្អស់នៅកម្ពុជា និងបទបញ្ញាត្តិមួយចំនួនដែលបានអនុវត្តន៍ក្នុងវិស័យធានារ៉ាប់រង និងកាន់តែលម្អិតពីប្រវត្តិរបស់ក្រុមហ៊ុនកម្ពុជារី គោលបំណងបេសកម្មរបស់ក្រុមហ៊ុន រចនាសម្ព័ន្ធនៃការគ្រប់គ្រង ជាពិសេសបានយល់ច្បាស់ពីកញ្ចប់សេវាកម្មធានារ៉ាប់រងបន្តរបស់ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជារី" ព្រមជាមួយនឹងគន្លឹះនៃការគ្រប់គ្រងដឹកនាំការងារមួយចំនួនដែលក្រុមហ៊ុនបានផ្តល់ឱ្យ។ ក្រុមហ៊ុនកម្ពុជារីក៏បានអភិវឌ្ឍខ្លួនយ៉ាងលឿនលើនៅវិស័យធានារ៉ាប់រងក្នុងប្រទេសកម្ពុជា ដោយមានការពង្រីកដៃគូសហការកាន់តែច្រើននៅក្នុងប្រទេស និងដៃគូសហការជាមួយក្រុមហ៊ុនធំៗមួយចំនួនដែលកំពុងមានវត្តមានក្នុងប្រទេសកម្ពុជា។

តាមការសិក្សាស្រាវជ្រាវអំពីធានារ៉ាប់រងបន្តរបស់ក្រុមហ៊ុនកម្ពុជារីកន្លងមកបានបង្ហាញថា កម្ពុជារីជាក្រុមហ៊ុនបម្រើសេវាកម្មធានារ៉ាប់រងតែមួយគត់ នៅក្នុងប្រទេសកម្ពុជាធំដែលមានអាយុកាល២២ឆ្នាំហើយ។ កម្ពុជារី ទទួលបានសន្ទុះនៃការគ្រាំទ្រពីសំណាក់អតិថិជនជាច្រើន ពីមួយឆ្នាំទៅមួយឆ្នាំដោយសារតែកម្ពុជារី ផ្តល់លក្ខខណ្ឌនៃការ ប្រើប្រាស់សេវាកម្មធានារ៉ាប់រងដ៏ល្អឥតខ្ចោះរបស់ ក្រុមហ៊ុនសុកម្ពុជារី។ ក្រុមហ៊ុននេះក៏មានចំណុចខ្វះខាតមួយចំនួនតូចដែលយើងខ្ញុំបានលើកយក មកបង្ហាញដើម្បីបង្កើនគុណភាពនៃការផ្តល់សេវាកម្មធានារ៉ាប់រងដែលល្អបំផុតសម្រាប់អតិថិជន។ ជាការពិតណាស់ការយល់ដឹងអំពីសេវាកម្មធានារ៉ាប់រងនៅក្នុងប្រទេសកម្ពុជាយើងនៅមានកម្រិត ប្រជាជនជាច្រើននៅមានការភ័នច្រឡំ ដូច្នេះនេះវាជាឱកាសដ៏ល្អមួយចំពោះកម្ពុជារីការពង្រីកខ្លួនផ្សព្វផ្សាយនៅតាមបណ្តាខេត្តផ្សេងៗ ដើម្បីឱ្យវិស័យនេះកាន់តែទូលំទូលាយជាពិសេសក្រុមហ៊ុនមានអ្នកស្គាល់ច្រើន។

# មាតិកា

ទំព័រ

អារម្ភកថា ........ i

រចនាសម្ព័ន្ធក្រុម ........ ii

សេចក្តីថ្លែងអំណរគុណ ........ iii

អំណះអំណាង ........ iv

សេចក្តីសង្ខេបនៃការស្រាវជ្រាវ ........ v

មាតិកា ........ vi

**ជំពូកទី១**

**សេចក្តីផ្តើម**

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ១

១.៣ គោលបំណងនៃការស្រាវជ្រាវ ........ ២

១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ២

 ១.៤.១ ទំហំដែនកំណត់ ........ ២

 ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ ........ ២

១.៥ វិធីសាស្រ្តនៃការស្រាវជ្រាវ ........ ២

 ១.៥.១ ការប្រមូលទិន្នន័យបន្ទាប់ ........ ២

១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣

១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៣

**ជំពូកទី២**

**អត្ថប្រយោជន៍ដែលទទួលបានពីក្រុមហ៊ុនធានារ៉ាប់រងទូទៅបន្ត**

២.១ លក្ខណៈទូទៅនៃធានារ៉ាប់រង ........ ៥

 ២.១.១ និយមន័យធានារ៉ាប់រង ........ ៥

 ២.១.២ ប្រវត្តិនៃធានារ៉ាប់រង ........ ៥

 ២.១.៣ ទ្រឹស្តីនៃធានារ៉ាប់រង ........ ៦

២.២ កាតព្វកិច្ចដែលអ្នកត្រូវបានធានាត្រូវបំពេញ ដើម្បីទទួលបានអត្ថប្រយោជន៍ពីក្រុមហ៊ុនធានារ៉ាប់រងបន្ត ៦

 ២.២.១ និយមន័យធានារ៉ាប់រងបន្ត ........ ៦

 ២.២.២ ប្រវត្តិនៃធានារ៉ាប់រងបន្ត ........ ៧

 ២.២.៣ ទ្រឹស្តីនៃធីធានារ៉ាប់រងបន្ត ........ ៧

២.៣ អត្ថប្រយោជន៍ដែលទទួលបានពីការប្រើប្រាស់សេវាកម្មធានារ៉ាប់រងបន្ត ........ ៨

 ២.៣.១ និយមន័យអត្ថប្រយោជន៍ ........ ៨

២.៣.២ ផលប្រយោជន៍ដែលទទួលបានពីក្រុមហ៊ុនធានារ៉ាប់រងបន្ត ............ ៨

## ជំពូកទី៣

## អត្ថប្រយោជន៍ដែលទទួលបានពីក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា " កម្ពុជា រី"

៣.១ ស្ថានភាពទូទៅរបស់ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជារី"
៣.១.១ ប្រវត្តិរបស់ក្រុមហ៊ុន ............ ១១
៣.១.២ និមិត្តសញ្ញារបស់ក្រុមហ៊ុន ............ ១២
៣.១.៣ ការចាប់ដៃគូសហការ ............ ១៣
៣.១.៤ បេសកកម្ម ទស្សនវិស័យ និងគុណតម្លៃ ............ ១៤
៣.១.៥ រចនាសម្ព័ន្ធរបស់ក្រុមហ៊ុន ............ ១៥
៣.២ កាតព្វកិច្ចដែលអ្នកត្រូវបានធានាត្រូវបំពេញ ដើម្បីទទួលបានអត្ថប្រយោជន៍ពីក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា"កម្ពុជា រី"
៣.២.១ ការចុះកិច្ចសន្យាធានារ៉ាប់រង ............ ១៩
៣.២.២ កាតព្វកិច្ចដែលអ្នកត្រូវបានធានាត្រូវបំពេញ ............ ១៩
៣.៣ អត្ថប្រយោជន៍ដែលទទួលបានពីក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជា រី" ............ ២០
៣.៣.១ ផលិតផល និងការគាំទ្រទីផ្សារ ............ ២០
៣.៣.២ ស្ថានភាពទីផ្សារ ............ ២០
៣.៣.៣ ការវាយតម្លៃស្ថានភាពទីផ្សារ ............ ២១
៣.៣.៤ អត្ថប្រយោជន៍នៃការប្រើប្រាស់សេវាធានារ៉ាប់រងបន្តរបស់កម្ពុជារី ............ ២២
៣.៣.៥ ការចូលរួមអភិវឌ្ឍ ............ ២៣

## ជំពូកទី៤

## ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង ............ ២៤
៤.២ ការវិភាគលើចំណុចខ្សោយ ............ ២៥

## ជំពូកទី៥

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន ............ ២៦
៥.២ ការផ្តល់អនុសាសន៍ ............ ២៧
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជា ជាប្រទេសដែលធ្លាប់បានជួបប្រទះនូវសង្គ្រាមជាច្រើន ជាពិសេសរបបកម្ពុជាប្រជាធិបតេយ្យ ដែលធ្វើឱ្យប្រទេសកម្ពុជារងនូវការខូចខាតយ៉ាងខ្លាំងលើគ្រប់វិស័យដូចជា វិស័យអប់រំ ឧស្សាហកម្ម សុខាភិបាល ហេដ្ឋារចនាសម្ព័ន្ធ ។ល។ ក្នុងកំឡុងពេលនោះ សេដ្ឋកិច្ចរបស់ ប្រទេសកម្ពុជា មានការធ្លាក់ចុះយ៉ាងខ្លាំង ក៏ប៉ុន្តែ នៅក្នុងពេលបច្ចុប្បន្ននេះ យើងសង្កេតឃើញថាប៉ុន្មានទសវត្សរ៍ចុងក្រោយ ក្រោយពីសង្គ្រាមពុំរ៉ៃ កម្ពុជាបានអភិវឌ្ឍ ខ្លួនយ៉ាងឆាប់រហ័ស រហូតទទួលបានការទទួលស្គាល់ជាសាកល។ ប្រទេសកម្ពុជាមានការអភិវឌ្ឍលើគ្រប់វិស័យ ជាពិសេសវិស័យឧស្សាហកម្មកាត់ដេរ វិស័យទេសចរណ៍ វិស័យកសិកម្ម វិស័យហិរញ្ញវត្ថុ ធនាគារ និងវិស័យធានារ៉ាប់រង ដែលជាវិស័យចម្បងដែលធ្វើឱ្យកំណើនសេដ្ឋកិច្ចប្រទេសកម្ពុជាមានការកើនឡើងយ៉ាងឆាប់រហ័សស្ទើរតែ គ្រប់វិស័យទាំងអស់ក្នុងនោះមានវិស័យធានាគារហិរញ្ញវត្ថុ និងសេវាកម្មធានារ៉ាប់រងដោយសារបានបង្ហាញឱ្យឃើញ នូវសក្តានុពលនៃការកើនឡើងជាលំដាប់នៃការប្រើប្រាស់ សេវាកម្មនេះនាពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ជាមួយ គ្នានេះរាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការជួយពង្រឹង និងពង្រីកវិស័យនេះដោយបង្កើតគម្រោង និងសេវាកម្មមួយចំនួនដើម្បីបម្រើតម្រូវត្រូវការរបស់អ្នកប្រើប្រាស់ និងត្រូវបានគេទទួលស្គាល់ថាជាវិស័យមួយដែល មានសារៈសំខាន់ផងដែរក្នុងការជំរុញក្នុងការអភិវឌ្ឍប្រទេសជាតិឱ្យកាន់តែរីកចម្រើន។

ទន្ទឹមនឹងនេះក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជា រី" ជាក្រុមហ៊ុនក្នុងស្រុកមួយដែលទទួលបានការ ទទួលស្គាល់ និងទុកចិត្តពីសំណាក់សាធារណជនបានរួមចំណែកដ៏ធំមួយផងដែរក្នុងការធានារ៉ាប់រងបន្តទៅ លើហានិភ័យផ្សេងៗនៅកម្ពុជា។ ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជារី" បានផ្តល់នូវសេវាកម្មធានារ៉ាប់រងទូទៅ និងអាយុជីវិតរួមមាន សេវាផ្តល់ដំណោះស្រាយ ការផ្ទេរហានិភ័យសមស្រប ផ្តល់សេវាកម្មធានារ៉ាប់រងបន្តទូលំ ទូលាយ និងប្រគួតប្រជែងលើគ្រប់ហានិភ័យទាំងធានារ៉ាប់រងទូទៅ និងអាយុជីវិត ព្រមទាំងបានផ្តល់សេវាដែល ផ្តោតទៅលើការអភិវឌ្ឍវិជ្ជាជីវៈធានារ៉ាប់រងដើម្បីជួយក្រុមហ៊ុនធានារ៉ាប់រងទាំងអស់។ ទាំងនេះគឺជាដែល ហេតុបណ្តាលឱ្យក្រុមហ៊ុនមានការរីកចម្រើនឥតឈប់ឈរ។ ភាពជោគជ័យរបស់ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជារី" ដោយសារតែក្រុមហ៊ុនមានសេវាកម្មដ៏ល្អ អាចដោះស្រាយបញ្ហា ឬហានិភ័យបានទាន់ពេលវេលា។

ហេតុដូចនេះហើយ ទើបយើងខ្ញុំសម្រេចចិត្តជ្រើសរើសយកប្រធានបទ "អត្ថប្រយោជន៍ដែលទទួលបាន ពីក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា កម្ពុជា រី"មកសិក្សាស្រាវជ្រាវ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

មានដំណើរទៅមុខដោយរលូន និងកាត់បន្ថយនូវហានិភ័យ ដូច្នេះអង្គភាពនីមួយៗមិនដែលព្រងើយ កន្តើយនឹងបញ្ហានេះឡើយ។ នេះគឺដោយសារតែ ការធានារ៉ាប់រងបន្តនឹងផ្តល់ឱ្យអង្គភាពទាំងនោះនូវសំណងទៅ លើហានិភ័យដែលបានកើតឡើងជាកត្តានាំមកនូវភាពជោគជ័យចំពោះអង្គភាពទាំងមូល។ ដូច្នេះ ដើម្បីដឹងឱ្យ កាន់តែច្បាស់អំពីទ្រឹស្តី និងការអនុវត្តជាក់ស្តែងរបស់ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជា រី" យើងបានធ្វើ ការស្រាវជ្រាវ និងសិក្សាស្វែងយល់ឱ្យកាន់តែស៊ីជម្រៅទៅលើការធានារ៉ាប់រងរបស់ក្រុមហ៊ុនដោយផ្ទាល់។

១. ដើម្បីទទួលបានអត្ថប្រយោជន៍ពីក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជារី" តើអ្នកត្រូវបានធានារ៉ាប់រងត្រូវបំពេញកាតព្វកិច្ចបែបណាជាមួយក្រុមហ៊ុន ?

២. តើអត្ថប្រយោជន៍អ្វីខ្លះដែលអតិថិជនទទួលបានពីក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជា រី" ?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

វត្ថុបំណងនៃការស្រាវជ្រាវ គឺចង់ស្វែងយល់អំពីក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា"កម្ពុជារី"ដែលផ្តោតលើបញ្ហាសំខាន់ៗមួយចំនួនដូចខាងក្រោមៈ

- ការសិក្សាស្វែងយល់ពីទ្រឹស្តីនៃការធានារ៉ាប់រងបន្ត
- ការសិក្សាស្រាវជ្រាវពីស្ថានភាពទូទៅរបស់ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជារី"
- សិក្សាស្វែងយល់អំពីកាតព្វកិច្ចរបស់អ្នកត្រូវបានធានាត្រូវបំពេញ
- ការសិក្សាអំពីអត្ថប្រយោជន៍ដែលទទួលបានពីក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា"កម្ពុជារី"
- ស្វែងយល់អំពីចំណុចខ្លាំងនិងចំណុចខ្សោយ
- ការធ្វើសេចក្តីសន្និដ្ឋាន និងផ្តល់អនុសាសន៍ស្តីពី ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជារី"។

## ១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំដែនកំណត់

ក្នុងការស្រាវជ្រាវនេះត្រូវបានកំណត់យកមកពន្យល់ និងបកស្រាយតែទៅលើការទទួលបានអត្ថប្រយោជន៍ពីការប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុនធានារ៉ាប់រងបន្តដែលមានក្នុងប្រទេសកម្ពុជា។ ដោយការស្រាវជ្រាវក្នុងជំពូកនេះមានរយៈពេលមួយខែចាប់ ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៤ដល់ថ្ងៃទី២០ ខែមករា ឆ្នាំ២០២៥។ ការស្រាវជ្រាវកំណត់យកទិន្ន័យតាមរយៈគេហៈទំព័រទាំងឡាយដែលទាក់ទងនឹងប្រធានបទ ជាពិសេសគេហៈទំព័រផ្ទាល់របស់ក្រុមហ៊ុនកម្ពុជា រី ដែលមានទីតាំងស្ថិតនៅ ផ្ទះលេខ៣ផ្លូវលេខ១៣៤សង្កាត់មិត្តភាពខណ្ឌ៧មករារាជធានីភ្នំពេញ។

### ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវទៅលើប្រធានបទ "អត្ថប្រយោជន៍ដែលទទួលបានពីក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា កម្ពុជា រី" មានវិសាលភាពឱ្យអ្នកស្រាវជ្រាវយល់ដឹងអំពីអត្ថប្រយោជន៍ដែលទទួលបានពីក្រុមហ៊ុនធានារ៉ាប់រងបន្តប្រភេទធានារ៉ាប់រងបន្ត និងកាតព្វកិច្ចរបស់អ្នកត្រូវបានធានា ដោយការដកស្រង់ទិន្ន័យនេះគិតចាប់ពីឆ្នាំ ២០២៣ ដល់ឆ្នាំ ២០២៤។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

ការស្រាវជ្រាវបានប្រើប្រាស់តាមវិធីសាស្រ្តបែប គុណវិស័យ ហើយទិន្នន័យដែលពួកយើងខ្ញុំប្រមូលមកត្រូវបានផ្អែកទៅលើកម្រងឯកសារនានានៅក្នុងច្បាប់ព្រះរាជក្រមស្តីពីធានារ៉ាប់រង គេហទំព័រឯកសារស្រាវជ្រាវបញ្ចប់ការសិក្សារបស់និស្សិតជំនាន់មុនៗ និងគេហទំព័ររបស់IRCដើម្បីយល់ដឹងអំពីសេវាធានារ៉ាប់រងបន្តកាតព្វកិច្ច និងអត្ថប្រយោជន៍ដែលទទួលបានពីក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជារី"។

### ១.៥.១ ការប្រមូលទិន្នន័យបន្ទាប់

សម្រាប់សំណួរស្រាវជ្រាវទី១៖ ការស្រាវជ្រាវនេះប្រើប្រាស់តាមបែបវិធីគុណវិស័យដូចជា តាមរយៈកម្រងឯកសារនានានៅ ក្នុងច្បាប់ព្រះរាជក្រមស្តីពីធានារ៉ាប់រង គេហទំព័រឯកសារស្រាវជ្រាវបញ្ចប់ការសិក្សា

របស់និស្សិតជំនាន់មុនៗ ដើម្បីយល់ដឹងពីកាតព្វកិច្ចដែលអ្នកត្រូវបានជានាត្រូវបំពេញដើម្បីទទួលបានអត្ថប្រយោជន៍ពីក្រុមហ៊ុនជានារ៉ាប់រង។

សម្រាប់សំណួរស្រាវជ្រាវទី២៖ ការស្រាវជ្រាវនេះប្រើប្រាស់តាមបែបគុណវិស័យ តាមរយៈគេហទំព័ររបស់ IRC ដើម្បីយល់ដឹងអំពីអត្ថប្រយោជន៍ដែលទទួលបានពីក្រុមហ៊ុនជានារ៉ាប់រងបន្ត។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទនេះមានសារៈសំខាន់ និងអត្ថប្រយោជន៍ជាច្រើន ជាពិសេសចំពោះ

- **ចំពោះក្រុមអ្នកស្រាវជ្រាវផ្ទាល់**
  - បានយល់ដឹងពីសេវាកម្មរបស់ក្រុមហ៊ុនជានារ៉ាប់រង
  - ការកំណត់អត្ថប្រយោជន៍សម្រាប់អតិថិជន
  - ការការពារ និងគ្រប់គ្រងហានិភ័យ
  - ការផ្តល់ដំណោះស្រាយជូនអតិថិជន
  - ទទួលបានចំណេះដឹងថ្មីៗពីការស្រាវជ្រាវ ដើម្បីអភិវឌ្ឍចំណេះដឹង
  - ចេះធ្វើការងារជាក្រុម និងជួយកែលម្អចំណុចខ្វះខាតគ្នាទៅវិញទៅមក
  - មានទំនួលខុសត្រូវលើការស្រាវជ្រាវ
- **ចំពោះស្ថាប័ន**
  - បានដឹងពីចំណុចខ្លាំងនិងចំណុចខ្សោយរបស់ក្រុមហ៊ុនយកមកកែលម្អនិងអភិវឌ្ឍន៍
  - អតិថិជនកាន់តែជឿទុកចិត្ត
  - មានអតិថិជនស្គាល់កាន់តែច្រើន
- **ចំពោះសង្គម**
  - បានផ្សព្វផ្សាយចំណេះដឹងទៅដល់និស្សិតជំនាន់ក្រោយ
  - រក្សាទុកជាឯកសារសម្រាប់សិស្សប្អូនជំនាន់ក្រោយសិក្សាស្វែងយល់បន្ត។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

- ជំពូកទី១(សេចក្តីផ្តើម)៖ ដោយបានបែងចែកជាចំណុចតូចៗដែលបង្ហាញពីលំនាំបញ្ហានៃស្រាវជ្រាវ ចំណោទបញ្ហា គោលបំណងនៃការស្រាវជ្រាវ ដែនកំណត់ វិសាលភាពនៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ និងសារៈសំខាន់នៃការស្រាវជ្រាវ។
- ជំពូកទី២(រំលឹកទ្រឹស្តី)៖ គឺជាការជ្រើសរើសនូវទ្រឹស្តីដែលសំខាន់ៗ និងការពាក់ព័ន្ធជាពិសេសដល់ការស្រាវជ្រាវ ការជ្រើសរើសយកទស្សនៈ និងគំនិតល្អៗ ដើម្បីយកធ្វើជាបទពិសោធន៍ទុកជាការផ្តល់មតិយោបល់ផ្សេងៗ ព្រមទាំងបង្ហាញពីលក្ខណៈទូទៅរបស់សេវាកម្មជានារ៉ាប់រង ប្រវត្តិ ទ្រឹស្តីនិយមន័យក៏ដូចជាសារៈសំខាន់នៃជានារ៉ាប់រង។
- ជំពូកទី៣(លទ្ធផលនៃការស្រាវជ្រាវ)៖ សរសេរពីដំណើរការជាក់ស្តែង ស្ថានភាពទូទៅរបស់ក្រុមហ៊ុនជានារ៉ាប់រងបន្តកម្ពុជា "កម្ពុជា រី" គោលដៅ ទស្សនៈវិស័យ ការចាប់ដៃគូសហការ បេសកកម្ម គោលនយោបាយ កាតព្វកិច្ច និងអត្ថប្រយោជន៍ដែលទទួលបានពីក្រុមហ៊ុនកម្ពុជា រី

- ជំពូកទី៤(ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ)៖ តាមការស្រាវជ្រាវរបស់ក្រុមយើងខ្ញុំកន្លងមក និងការមើលលើភាពជាក់ស្តែងអាចឱ្យយើងសន្និដ្ឋាន និងវាយតម្លៃលើចំណុចខ្លាំង និងចំណុចខ្សោយរបស់ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជារី" បាន។
- ជំពូកទី៥ (សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍)៖ បន្ទាប់ពីធ្វើការវិភាគ និងវាយតម្លៃរួចមក យើងបានធ្វើការសន្និដ្ឋានទៅលើប្រធានបទ និងការផ្តល់មតិយោបល់ ឬការផ្តល់ជាអនុសាសន៍ខ្លះៗសម្រាប់ការកែលម្អ និងអាចធ្វើឱ្យក្រុមហ៊ុនកាន់តែមានភាពប្រសើរឡើងថែមទៀត។

# ជំពូកទី២

# អត្ថប្រយោជន៍ដែលទទួលបានពីក្រុមហ៊ុនធានារ៉ាប់រងបន្ត

## ២.១ លក្ខណៈទូទៅនៃធានារ៉ាប់រង

### ២.១.១ និយមន័យធានារ៉ាប់រង

**ធានារ៉ាប់រង** គឺមានលក្ខណៈផ្សេងៗគ្នាជាច្រើនទៅតាមទស្សនៈនៃមេរៀនរួមបញ្ចូលច្បាប់សេដ្ឋកិច្ច ប្រវត្តិសាស្ត្រ ឯកទេសនៃធានារ៉ាប់រង ទ្រឹស្តីហានិភ័យ និងសង្គម។ ជាការពិតនិយមន័យនៃធានារ៉ាប់រងយើងមិនអាចកំណត់បាននូវអត្ថន័យជាក់លាក់ណាមួយឡើយប៉ុន្តែយើងអាចដឹងពីលក្ខខណ្ឌរបស់វារាល់គម្រោង នៃធានារ៉ាប់រង។ ទោះបីជាយ៉ាងណាក៏ដោយមុននឹងបកស្រាយលើនិយមន័យធានារ៉ាប់រងដំបូងត្រូវបង្ហាញពី ចរិតលក្ខណៈ និងចំណុចសំខាន់ៗនៃគម្រោងពិតរបស់ធានារ៉ាប់រងត្រូវបានបង្កើតឡើង[1]។

**ធានារ៉ាប់រង** គឺជាកិច្ចសន្យារវាងភាគីទាំងពីរ ដែលភាគីម្ខាងអ្នកធានាយល់ព្រមទូទាត់សងការខូចខាតរបស់ភាគីម្ខាងទៀតអ្នកធានារ៉ាប់រងជំនួសឱ្យការទូទាត់ការពិចារណាហៅថាបុព្វលាភ។ ដូច្នេះការធានារ៉ាប់រងគឺជា ឧបករណ៍គ្រប់គ្រងហានិភ័យ ដើម្បីការពារប្រឆាំងនឹងការខាតបង់ជាបន្តបន្ទាប់ និងជាយថាហេតុ។ វាគឺជាបច្ចេកទេសសហការនៃការចែកចាយហានិភ័យលើមនុស្សមួយចំនួនធំដែលប្រឈមនឹងហានិភ័យបែបនេះ ហើយចង់ការពារប្រឆាំងនឹងវា[2]។

**ធានារ៉ាប់រង** គឺសំដៅដល់ការធ្វើកិច្ចសន្យាធានារ៉ាប់រងក្នុងនោះអ្នកត្រូវបានធានារ៉ាប់រងត្រូវបានបង់នូវបុព្វលាភធានារ៉ាប់រងឱ្យទៅក្រុមហ៊ុនធានារ៉ាប់រង ហើយក្រុមហ៊ុនធានារ៉ាប់រងត្រូវធ្វើសំណងដល់ការខូតខាត ឬការបាត់បង់ទ្រព្យសម្បត្តិដែលបង្កឡើងដោយហេតុការណ៍គ្រោះថ្នាក់ ឬក៏ធ្វើសំណងនៅពេលដែលអ្នកត្រូវបានធានារ៉ាប់រង ស្លាប់ របួស ពិការ មានជំងឺ ឬនៅពេលដែលបុគ្គលនោះឈានដល់កាលកំណត់ណាមួយដែលភាគីទាំងពីរបានព្រមព្រៀងគ្នាដូច មានចែងក្នុងកិច្ចសន្យាធានារ៉ាប់រង[3]។

### ២.១.២ ប្រវត្តិនៃធានារ៉ាប់រង

ការអភិវឌ្ឍវិស័យធានារ៉ាប់រងនៅកម្ពុជាបានចាប់ផ្តើមនៅឆ្នាំ១៩៥៦ប៉ុន្តែត្រូវបានរំខានដោយសាររបបខ្មែរក្រហមក្នុងឆ្នាំ១៩៧៥ ។ ការអភិវឌ្ឍនៃវិស័យនេះបានចាប់ផ្តើមឡើងវិញនៅដើមទសវត្សរ៍១៩៩០ជាមួយនឹងបទប្បញ្ញត្តិតិចតួចដែលចាំបាច់ដាក់ស្តែងនៅពេលនោះ ក្នុងគោលបំណងចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងដើម្បីធ្វើសំណងជូនជនរងគ្រោះចំពោះការខាតបង់ដែលបណ្តាលមកពីគ្រោះមហន្តរាយធម្មជាតិ គ្រោះថ្នាក់ចៃដន្យ និងព្រឹត្តិការណ៍អកុសលផ្សេងៗទៀតដែលអាចកើតមានឡើង។ ទោះជាយ៉ាង

1 George E. Rejda and Rejda, George E. (2008). *Principle of Risk Management and Insurance* (12 ed.). United States of America: Pearson Education, Inc., Page 20. 644 Page.

2 DDE, GJUS & T, Hisar. (2012). *Fundamentals of Insurance*. P.4. Retrieved 2025, August 12 from: https://share.google/JoC8Y4z89SWSWjfpr

3 Linked in. Ecoinsoft Solution, (2023). *តើអ្វីទៅជាការធានារ៉ាប់រង ?* Retrieved 2025, August 15 from https://www.linkedin.com/pulse/តអវទជ-ករធនរបរង-ecoinsoft

ណាក៏ដោយ មុខងារពេញលេញនៃការធានារ៉ាប់រងពេលគឺ ធានារ៉ាប់រងទូទៅបានចាប់ផ្តើម ជាមួយនឹងច្បាប់ធានារ៉ាប់រងនៅឆ្នាំ២០០០ និងបទបញ្ញត្តិមួយចំនួនទៀតដែលបានដាក់ចេញក្នុងឆ្នាំបន្តបន្ទាប់។

**២.១.៣ ទ្រឹស្តីនៃធានារ៉ាប់រង**

ការធានារ៉ាប់រងពឹងផ្អែកយ៉ាងខ្លាំងលើ **"ច្បាប់នៃចំនួនជាច្រើន"**។ នៅក្នុងចំនួនប្រជាជនដូចគ្នាធំៗ គេអាចប៉ាន់ស្មានប្រេកង់ធម្មតានៃព្រឹត្តិការណ៍ទូទៅដូចជា ការស្លាប់ និងគ្រោះថ្នាក់។ ការខាតបង់អាចត្រូវបានទស្សន៍ទាយដោយភាពត្រឹមត្រូវសមហេតុផល ហើយភាពត្រឹមត្រូវកើនឡើងនៅពេលដែលទំហំនៃក្រុមពង្រីក។ តាមទស្សនៈទ្រឹស្តីវាគឺ អាចធ្វើទៅបានដើម្បីលុបបំបាត់ហានិភ័យសុទ្ធទាំងអស់ប្រសិនបើក្រុមហ៊ុនធំគ្មានដែនកំណត់ត្រូវបានជ្រើសរើស។ តាមទស្សនៈរបស់អ្នកធានាហានិភ័យដែលអាចធានាបានត្រូវតែបំពេញតាមដូចខាងក្រោម៖

១. វត្ថុដែលត្រូវធានារ៉ាប់រងត្រូវតែមានច្រើន និងមានភាពដូចគ្នាគ្រប់គ្រាន់ ដើម្បីអនុញ្ញាតឱ្យមាន ការគណនាយ៉ាងជិតស្និទ្ធសមហេតុផលនៃប្រេកង់ដែលទំនង និងភាពធ្ងន់ធ្ងរនៃការខាតបង់។

២. វត្ថុធានារ៉ាប់រងមិនត្រូវទទួលរងនូវ ការបំផ្លិចបំផ្លាញក្នុងពេលដំណាលគ្នាឡើយ។ ជាឧទាហរណ៍ ប្រសិនបើអគារទាំងអស់ដែលធានារ៉ាប់រងដោយក្រុមហ៊ុនធានារ៉ាប់រងមួយស្ថិតនៅក្នុងតំបន់ដែលទទួល រងនូវទឹកជំនន់ ហើយមានទឹកជំនន់កើតឡើង ការខាតបង់ចំពោះអ្នកធានារ៉ាប់រងអាចក្លាយជាមហន្តរាយ។

៣. ការបាត់បង់ដែលអាចកើតមានត្រូវតែកើតមានដោយចៃដន្យនៅក្នុងធម្មជាតិ និងលើសពីការគ្រប់គ្រង របស់អ្នកធានារ៉ាប់រង។ ប្រសិនបើការធានារ៉ាប់រងអាចបណ្តាលឱ្យបាត់បង់ ធាតុនៃភាពចៃដន្យ និងការព្យាករណ៍ នឹងត្រូវបានបំផ្លាញ។

៤. ត្រូវតែមានវិធីមួយចំនួនដើម្បីកំណត់ថា តើការបាត់បង់បានកើតឡើង ហើយតើការបាត់បង់នោះធំប៉ុណ្ណា។ នេះជាមូលហេតុដែលកិច្ចសន្យាធានារ៉ាប់រងបញ្ជាក់យ៉ាងច្បាស់ថា តើព្រឹត្តិការណ៍អ្វីត្រូវកើតឡើង អ្វីជាការខាតបង់ និងរបៀបដែលវាត្រូវបានវាស់វែង[4]។

## ២.២ ភាតព្វកិច្ចដែលអ្នកត្រូវបានធានាត្រូវបំពេញ ដើម្បីទទួលបានអត្ថប្រយោជន៍ពីក្រុមហ៊ុនធានារ៉ាប់រងបន្ត

**២.២.១ និយមន័យធានារ៉ាប់រងបន្ត**

**ធានារ៉ាប់រងបន្ត** ធានារ៉ាប់រងបន្តគាំទ្រក្រុមហ៊ុនធានារ៉ាប់រង។ ជាងនេះទៅទៀតឧស្សាហកម្មប្រភេទនេះត្រូវបានរៀបចំឡើងជាមួយនឹងអ្នកចូលរួមមួយផ្សេងទៀតហៅថា៖ ការធានារ៉ាប់រងបន្ត។ វាជាអាជីវកម្មដ៏ធំនិងមានភាពស្មុគស្មាញដែលគ្រប់គ្រងដោយអ្នកដែលមានជំនាញខ្ពស់។ សរុបមកក្រុមហ៊ុនធានារ៉ាប់រងបង់"បុព្វលាភ" ដល់ក្រុមហ៊ុនធានារ៉ាប់រងបន្ត ដើម្បីជួយពួកគេផ្នែកហិរញ្ញវត្ថុក្នុងករណីចាំបាច់។ ដូច្នេះនិយមន័យខ្លីមួយគឺថា ការធានារ៉ាប់រងបន្តគឺជាការធានារ៉ាប់រងសម្រាប់ក្រុមហ៊ុនធានារ៉ាប់រង[5]។

---

[4] Britannica Money, Mark Richard Greene. (2025, June 28). *Insurance*. Retrieved 2025, August 15 from https://www.britannica.com/money/insurance

[5] Safetynet. (2025, June 29). *តើអ្នកដឹងទេថាធានារ៉ាប់រងបន្តជាអ្វី?* Retrieved 2025, August 17 from https://share.google/O7zV8Y5CtSjkoc7pm

**ធានារ៉ាប់រងបន្ត** សំដៅដល់ប្រតិបត្តិការធានារ៉ាប់រងដែលក្រុមហ៊ុនធានារ៉ាប់រងដើមត្រូវបានធានារ៉ាប់រងដោយក្រុមហ៊ុនធានារ៉ាប់រងផ្សេងទៀតដែលជាក្រុមហ៊ុនធានារ៉ាប់រងបន្តនូវហានិភ័យមួយផ្នែកឬទាំងស្រុងដែលខ្លួនបានចុះកិច្ចសន្យាធានារ៉ាប់រង[6]។

**ធានារ៉ាប់រងបន្ត** ជារឿយៗហៅថាជាការធានារ៉ាប់រងសម្រាប់ក្រុមហ៊ុនធានារ៉ាប់រង គឺជាកិច្ចសន្យារវាងក្រុមហ៊ុនធានារ៉ាប់រងបន្តនិងក្រុមហ៊ុនធានារ៉ាប់រង។ នៅក្នុងកិច្ចសន្យានេះក្រុមហ៊ុនធានារ៉ាប់រងត្រូវបានគេស្គាល់ថា ជាភាគីដែលផ្តល់សិទ្ធិផ្ទេរហានិភ័យធានារ៉ាប់រងមួយចំនួនរបស់ខ្លួនទៅឱ្យក្រុមហ៊ុនធានារ៉ាប់រងបន្ត[7]។

**ធានារ៉ាប់រងបន្ត** ជាធានារ៉ាប់រងដែលបានទិញដោយក្រុមហ៊ុនធានារ៉ាប់រង ដើម្បីការពារខ្លួនប្រឆាំងនឹងការទាមទារដ៏ធំពីអតិថិជនរបស់ខ្លួន[8]។

**២.២.២ ប្រវត្តិនៃធានារ៉ាប់រងបន្ត**

ធានារ៉ាប់រងបន្ត (Reinsurance) មានប្រវត្តិជាយូរមកហើយ ដោយបើតាមការសិក្សាផ្សេងៗ សេវានេះបានកើតឡើងដំបូងគេនៅក្នុងប្រទេសអឺរ៉ុប ក្នុងសតវត្សទី 14។ វាបានកើតចេញពីតម្រូវការរបស់ក្រុមហ៊ុនធានារ៉ាប់រងដើមក្នុងការកាត់បន្ថយហានិភ័យដោយផ្ទេរផ្នែកខ្លះនៃហានិភ័យនោះទៅឱ្យក្រុមហ៊ុនផ្សេងទៀត។ នេះជារបៀបដែលធានារ៉ាប់រងបន្តបានចាប់ផ្តើម និងរីកចម្រើនជាបន្តបន្ទាប់។ ដំណើរបណ្តោះអាសន្ននៅសតវត្សទី 14: ករណីដំបូងបង្ហាញពីការធានារ៉ាប់រងបន្តគឺនៅប្រទេសអ៊ីតាលី និងអេស្ប៉ាញ (Spain) ទាក់ទងនឹងការដឹកជញ្ជូនទំនិញតាមសមុទ្រ។ សតវត្សទី19: ការអភិវឌ្ឍនៃសេវាធានារ៉ាប់រងបន្តនៅអាល្លឺម៉ង់ជាពិសេសក្រុមហ៊ុន Cologne Re និង Munich Re ត្រូវបានបង្កើតឡើង។ សតវត្សទី 20-21: ធានារ៉ាប់រងបន្តបានក្លាយជាផ្នែកសំខាន់មួយនៃវិស័យហិរញ្ញវត្ថុ និងធានារ៉ាប់រងនៅលើកម្រិតអន្តរជាតិ។ គោលបំណងសំខាន់នៃ ធានារ៉ាប់រងបន្ត (Reinsurance) មានដូចជាកាត់បន្ថយហានិភ័យនៃក្រុមហ៊ុនធានារ៉ាប់រងដើម បង្កើនសមត្ថភាពទទួលបន្ទុក ស្ថិតស្ថេរភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ការផ្តល់សេវាបន្ថែមក្នុងការគ្រប់គ្រងហានិភ័យ។ នៅកម្ពុជាវិស័យធានារ៉ាប់រងបន្តកំពុងអភិវឌ្ឍជាបន្តបន្ទាប់។ ដោយក្រុមហ៊ុនធានារ៉ាប់រងបន្តដំបូងគឺ “Cambodia Re” ដែលបានបង្កើតឡើងនៅក្នុងគោលបំណងជួយបណ្តាញធានារ៉ាប់រងក្នុងស្រុកក្នុងការចែករំលែកហានិភ័យ និងរួមចំណែកក្នុងការអភិវឌ្ឍវិស័យនេះ[9]។

**២.២.៣ ទ្រឹស្តីនៃធានារ៉ាប់រងបន្ត**

ការធានារ៉ាប់រងបន្តជួយក្រុមហ៊ុនធានារ៉ាប់រងក្នុងការគ្រប់គ្រងហានិភ័យរបស់ពួកគេ ដោយស្រូបយកការខាតបង់មួយចំនួនរបស់ពួកគេ។ ការធានារ៉ាប់រងបន្តធ្វើឱ្យលទ្ធផលនៃក្រុមហ៊ុនធានារ៉ាប់រងមានស្ថេរភាព

---

[6] អនុក្រឹត្យលេខ២៧៥ ឆ្នាំ២០២១ *ស្តីពីការធានារ៉ាប់រង* ទំព័រទី៣ ២៩ទំព័រ Retrieved 2025, August 17 from https://share.google/5mxswnUcYtG3bhwut

[7] Investopedia. CAROLIN BANTON. (Updated 2025, February 28). *Reinsurance Definition, Types, and How It Works*. Retrieved 2025, August 17 from https://www.investopedia.com/terms/r/reinsurance.asp

[8] Cambridge Dictionary. *Reinsurance*. Retrieved 2025, August 17 from https://dictionary.cambridge.org/dictionary/english/reinsurance

[9] Google share. (2021). *History of insurance*: https://share.google/FR5r7ApNThluelWwB

និងអនុញ្ញាតឱ្យមានការរីកចម្រើន និងការច្នៃប្រឌិតបន្ត។ ដោយសារតែប្រាក់ដ៏ច្រើនដែលពួកគេបានបណ្តាក់ទុកក្នុងទីផ្សារហិរញ្ញវត្ថុ ក្រុមហ៊ុនធានារ៉ាប់រងបន្តក៏រួមចំណែកយ៉ាងសំខាន់ដល់សេដ្ឋកិច្ចពិតប្រាកដផងដែរ។

ទោះបីជាពួកគេត្រូវបានគេស្គាល់តិចតួចកាលពីអតីតកាលក៏ដោយ ក៏ក្រុមហ៊ុនធានារ៉ាប់រងបន្តកំពុងទទួលបានការទទួលស្គាល់នៅក្នុងពន្លឺនៃគ្រោះមហន្តរាយធំៗ សម្រាប់តួនាទីដែលពួកគេដើរតួក្នុងការជួយក្រុមហ៊ុនធានារ៉ាប់រង រដ្ឋាភិបាល និងសង្គមទាំងមូលក្នុងការដោះស្រាយជាមួយនឹងហានិភ័យនាពេលបច្ចុប្បន្ននេះ[10]។

## ២.៣ អត្ថប្រយោជន៍ដែលទទួលបានពីការប្រើប្រាស់សេវាកម្មធានារ៉ាប់រងបន្ត

### ២.៣.១ និយមន័យអត្ថប្រយោជន៍

**អត្ថប្រយោជន៍** គឺជាអំណាចនៃទំនិញ ឬសេវាកម្មដើម្បីបំពេញតម្រូវការ និងចំណង់ចំណូលចិត្តរបស់អតិថិជន។

**អត្ថប្រយោជន៍** គឺជាអំណោយអ្វីមួយ កម្រៃ តម្លៃឈ្នួល រង្វាន់ ឬកម្រៃជើងសាដែលមិនមានការអនុញ្ញាតដោយច្បាប់ជាធរមានជាទឹកប្រាក់ ឬជាវត្ថុមានតម្លៃ ឬជាទ្រព្យសម្បត្តិប្រភេទអ្វីមួយ"។

**អត្ថប្រយោជន៍** គឺជាការសប្បាយរីករាយ ការពេញចិត្ត ឬសុភមង្គលដែលបុគ្គលម្នាក់ទទួលបានពីការប្រើប្រាស់ទំនិញឬសេវាណាមួយ។ អត្ថប្រយោជន៍ អាចទទួលបានពីការធ្វើសកម្មភាពណាមួយ ដូចជាការដើរលេង ការទស្សនាទេសភាព ឬការលេងល្បែងប្រជាប្រិយ។

### ២.៣.២ ផលប្រយោជន៍ដែលទទួលបានពីធានារ៉ាប់រងបន្ត

ការធានារ៉ាប់រងបន្តមានសារៈសំខាន់ណាស់ ព្រោះវាជួយក្រុមហ៊ុនធានារ៉ាប់រងគ្រប់គ្រងហានិភ័យការប្រែប្រួល និងការពារស្ថិរភាពហិរញ្ញវត្ថុរបស់ពួកគេ។ វាក៏ជួយលើកកម្ពស់ទីផ្សារ និងកំណើនសេដ្ឋកិច្ចផងដែរ។ លើសពីនេះទៅទៀតការធានារ៉ាប់រងបន្តមានអត្ថប្រយោជន៍ជាច្រើនទៀតដូចជាៈ

**១. ការធានារ៉ាប់រងបន្តផ្តល់ឱ្យក្រុមហ៊ុនដើម្បីទទួលយកអតិថិជនកាន់តែច្រើនៈ** អត្ថប្រយោជន៍ចម្បងនៃការធានារ៉ាប់រងបន្ត គឺដើម្បីការពារក្រុមហ៊ុនពីការក្ស័យធន។ វាធានាថាក្រុមហ៊ុនអាចធ្វើការទូទាត់លើការទាមទារទាំងអស់របស់អតិថិជន។ នេះពង្រឹងមូលដ្ឋានគ្រឹះរបស់ក្រុមហ៊ុន និងផ្តល់ឱ្យពួកគេនូវទំនុកចិត្តក្នុងការទទួលយកហានិភ័យកាន់តែច្រើន និងផ្តល់សេវាកម្មរបស់ពួកគេទៅកាន់អតិថិជនបានកាន់តែច្រើន។

**២. ការធានារ៉ាប់រងបន្តកាត់បន្ថយនូវបន្ទុកហានិភ័យៈ** នៅពេលដែលក្រុមហ៊ុនធានារ៉ាប់រងតែមួយធានារ៉ាប់រងអតិថិជនមួយចំនួនធំ ពួកគេនឹងប្រឈមនៅហានិភ័យយ៉ាងច្រើន។ ការធានារ៉ាប់រងបន្ត គឺជាយុទ្ធសាស្ត្រដ៏ល្អមួយ ដើម្បីកាត់បន្ថយហានិភ័យនោះដោយដាក់បន្ទុកមួយចំនួនលើក្រុមហ៊ុនធានាបន្តជំនួសឱ្យការទទួលបន្ទុកទាំងស្រុងដោយខ្លួនឯង។

**៣. ក្រុមហ៊ុនធានារ៉ាប់រងបន្តផ្តល់ជំបូន្មានដែលមិនអាចកាត់ថ្លៃបានៈ** នៅពេលដែលបុគ្គលម្នាក់ត្រូវការជំបូន្មានផ្នែកធានារ៉ាប់រង ពួកគេអាចងាកទៅរកក្រុមហ៊ុនធានារ៉ាប់រង។ ប៉ុន្តែក្នុងករណីក្រុមហ៊ុនធានារ៉ាប់រង

[10] Share.google. Swiss Re. (2015). *The essential guide to reinsurance*. Page 1. 180 Page. Retrieved 2025, August 15 from https://share.google/P0FhpYJGys6qjjpsm

ដែលទើបបង្កើតអាជីវកម្មថ្មី ឬមិនទាន់រីកចម្រើនក្លាយទៅជាស្ថាប័នធំ តើពួកគេអាចទៅរកជំបូន្មាននៅឯណា? គឺពួកគេអាចទទួលបានការប្រឹក្សាធានារ៉ាប់រងបានយ៉ាងល្អពីក្រុមហ៊ុនធានារ៉ាប់រងបន្ត។

**៤. ផ្តល់នូវស្ថិរភាពក្នុងអំឡុងពេលភាពតានតឹងផ្នែកហិរញ្ញវត្ថុ៖** ទោះបីជាក្រុមហ៊ុនធានារ៉ាប់រងមួយមានលទ្ធភាពបង់ការទាមទារជាច្រើនដែលបានធ្វើឡើងក្នុងរយៈពេលដ៏ខ្លីក៏ដោយ ការចេញនូវចំណាយរាល់ការទាមទារទាំងនោះអាចទុកវាឱ្យស្ថិតក្នុងស្ថានភាពហិរញ្ញវត្ថុធ្ងន់ធ្ងរ និងមិនមានស្ថិរភាពខ្លាំង។ ការធានារ៉ាប់រងបន្តជួយឱ្យក្រុមហ៊ុនធានារ៉ាប់រងបន្តនៅក្នុងអំឡុងពេលដ៏លំបាកទាំងនេះ។

**៥.ការធានារ៉ាប់រងបន្តធ្វើឱ្យថ្លៃដើមនៃបុព្វលាភមានស្ថិរភាព៖** ការធានារ៉ាប់រងបន្តជួយក្នុងស្ថេរភាពអត្រាបុព្វលាភ។ ជាធម្មតាអត្រាបុព្វលាភគឺត្រូវគេបានគណនាដោយផ្អែកលើការខាតបង់ដែលជួបប្រទះដោយក្រុមហ៊ុនធានារ៉ាប់រងនាពេលកន្លងមកដោយសារហានិភ័យដែលពាក់ព័ន្ធ។ ការធានារ៉ាប់រងបន្តយកហានិភ័យពីមុនទាំងអស់មកពិចារណា និងជួសជុលអត្រាបុព្វលាភដោយយោងទៅតាមប្រភេទផ្សេងៗនៃហានិភ័យក្រោមកិច្ចព្រមព្រៀងទៅវិញទៅមកដែលនាំឱ្យមានស្ថិរភាពនៃអត្រាបុព្វលាភ។

**៦. ការធានារ៉ាប់រងបន្តកាត់បន្ថយការប្រកួតប្រជែងក្នុងចំណោមក្រុមហ៊ុនធានារ៉ាប់រង៖** នៅពេលដែលក្រុមហ៊ុនធានារ៉ាប់រងពឹងផ្អែកលើគ្នាទៅវិញទៅមក ដើម្បីកាត់បន្ថយហានិភ័យរបស់ពួកគេ កិច្ចសហប្រតិបត្តិការនេះនាំឱ្យមានសុច្ឆន្ទៈភាពរវាងគ្នាទៅវិញទៅមកនៅក្នុងឧស្សាហកម្មនេះ។ ចាប់ពីពេលនេះតទៅ ការធានារ៉ាប់រងបន្តជួយគ្រប់គ្រងការប្រកួតប្រជែង និងលើកកម្ពស់សីលធម៌របស់និយោជិតក្នុងអាជីវកម្មធានារ៉ាប់រង

**៧. ការធានារ៉ាប់រងបន្តជួយក្នុងស្ថិរភាពប្រាក់ចំណេញ៖** ការធានារ៉ាប់រងបន្តជួយធ្វើឱ្យក្រុមហ៊ុនមានស្ថិរភាព ក្នុងគ្រប់ទំហំ រួមទាំងប្រាក់ចំណេញដែលទទួលបានដោយក្រុមហ៊ុនធានារ៉ាប់រង។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើហានិភ័យធំជាងនេះនៅតែរក្សាដោយក្រុមហ៊ុនធានារ៉ាប់រងដើម ប្រាក់ចំណេញរបស់ពួកគេអាចរងទុក្ខយ៉ាងខ្លាំងដោយការទាមទារធំ។

**៨. ការធានារ៉ាប់រងបន្តអាចជួយកាត់បន្ថយចំនួនគោលនយោបាយធានារ៉ាប់រង ដែលអតិថិជនត្រូវការទិញ៖** ដើម្បីធ្វើការរាប់បញ្ចូលប្រសិនបើអតិថិជនណាចង់បានការធានាអចលនទ្រព្យដែលមានតម្លៃថ្លៃខ្លាំងប្រឆាំងទៅនឹងគ្រោះមហន្តរាយណាមួយហើយគ្មានក្រុមហ៊ុនបុគ្គលណាម្នាក់អាចទទួលយកហានិភ័យដ៏ធំបែបនេះបាន។ ក្នុងស្ថានភាពបែបនេះ អតិថិជននឹងត្រូវ ទៅជួបក្រុមហ៊ុនធានារ៉ាប់រងជាច្រើនដោយខ្លួនឯង ហើយចូលទៅក្នុងកិច្ចព្រមព្រៀងធានារ៉ាប់រងបុគ្គលផ្សេងៗលើអចលនទ្រព្យដូចគ្នា។ នេះគឺបានរួមបញ្ចូលទាំងការចំណាយសន្ទឹកសន្ធាប់បាត់បង់ពេលវេលាដ៏មានតម្លៃហើយវាធ្វើឱ្យថយល្បឿននៃគម្របការពារ។ការធានារ៉ាប់រងបន្តជួយអតិថិជនជៀសវាងកិច្ចព្រមព្រៀងជាច្រើន ហើយគាត់ត្រូវបានគេតម្រូវឱ្យទិញគោលនយោបាយតែមួយពីក្រុមហ៊ុនធានារ៉ាប់រងតែមួយគត់។

**៩. ការធានារ៉ាប់រងបន្តការពារមូលនិធិធានារ៉ាប់រង៖** មូលនិធិធានារ៉ាប់រងរបស់អ្នកធានារ៉ាប់រង ត្រូវបានការពារយ៉ាងល្អដោយសារតែការធានារ៉ាប់រងបន្ត។ សុវត្ថិភាពបន្ថែម និងសន្តិភាពនៃចិត្ត គឺជាអត្ថប្រយោជន៍បន្ថែមនៃការធានារ៉ាប់រងបន្តសម្រាប់អ្នកធានារ៉ាប់រង និងក្រុមហ៊ុនដែលផ្តល់ការធានារ៉ាប់រង។

**១០. ការធានារ៉ាប់រងបន្តគឺល្អសម្រាប់អាជីវកម្មធានារ៉ាប់រង៖** អត្ថប្រយោជន៍ដ៏ធំបំផុតនៃការធានារ៉ាប់រងបន្ត គឺថាវាជួយក្នុងការលើកកម្ពស់អាជីវកម្មធានារ៉ាប់រង។ វាអនុញ្ញាតឱ្យក្រុមហ៊ុនធានារ៉ាប់រងគ្រប់រូបពង្រឹងអាជីវកម្មធានារ៉ាប់រងរបស់ពួកគេដោយសារហានិភ័យសរុប នឹងត្រូវបានចែកចាយក្នុងចំណោមក្រុមហ៊ុនធានារ៉ាប់រងបន្តផ្សេងទៀត។

**១១. វាគឺជាការវិនិយោគដ៏មានតម្លៃ៖** តើអ្នកណាយល់ច្បាស់ពីតម្លៃនៃការធានារ៉ាប់រងជាងក្រុមហ៊ុនធានារ៉ាប់រងខ្លួនឯង។ ដូច្នេះក្រុមហ៊ុនធានារ៉ាប់រងយល់ច្បាស់ពីសារៈសំខាន់នៃការវិនិយោគក្នុងការធានារ៉ាប់រងខ្លួនឯង និងកេរ្តិ៍ឈ្មោះរបស់ពួកគេ[11]។

[11] Life & General Insurance, (2021). *Advantages of Reinsurance*. Retrieved 2025, August 15 from https://www.lnginsurance.com/blog/advantages-of-reinsurance/

# ជំពូកទី៣

# អត្ថប្រយោជន៍ដែលទទួលបានពីក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា ″កម្ពុជា រី″

## ៣.១ ស្ថានភាពទូទៅរបស់ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា ‶កម្ពុជា រី″

### ៣.១.១ ប្រវត្តិក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា ‶កម្ពុជា រី″




**ទីតាំង៖ រាជធានីភ្នំពេញ**

ដើម្បីគាំទ្រទីផ្សារធានារ៉ាប់រងដែលទើបតែចាប់កំណើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា‶កម្ពុជារី″ ដែលត្រូវបានគេស្គាល់ឈ្មោះថា ‶កម្ពុជារី″ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០២ ដែលជាសហគ្រាសរដ្ឋ ក្រោមអាណាព្យាបាលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ដើម្បីទាញយកបទពិសោធន៍ជំនាញនៅក្នុងតំបន់នៃទីផ្សារធានារ៉ាប់រងដែលមានការរីកចម្រើននិងដោយមើលឃើញអំពីសក្តានុពលនៃអាជីវកម្មនៅក្នុងទីផ្សារធានារ៉ាប់រងនៅកម្ពុជាផងនោះក្រុមហ៊ុនកម្ពុជារី ក៏បានប្រែក្លាយខ្លួនទៅជាក្រុមហ៊ុនចម្រុះរដ្ឋក្នុងឆ្នាំ២០០៤ រវាងរាជរដ្ឋាភិបាលកម្ពុជាដែលតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមហ៊ុន Asian Insurance International Holding (AII) ដែលជាសម្ព័ន្ធនៃក្រុមហ៊ុនធានារ៉ាប់រងមួយចំនួននៅក្នុងតំបន់។

ក្រោយមកទៀត ភាគហ៊ុនិកយុទ្ធសាស្ត្រក្នុងស្រុកចំនួនពីរបានចូលរួមជាមួយក្រុមហ៊ុនកម្ពុជារីក្នុងឆ្នាំ២០១៩ដែលធ្វើឱ្យក្រុមហ៊ុនមានមូលដ្ឋានភាគហ៊ុនិកកាន់តែទូលំទូលាយទាំងផ្នែកហិរញ្ញវត្ថុនិងយុទ្ធសាស្ត្រ។

ក្នុងនាមជាក្រុមហ៊ុនធានារ៉ាប់រងបន្តរបស់ជាតិ ដែលមានវត្តមានរយៈពេលវែង នៅក្នុងទីផ្សារធានារ៉ាប់រងនៅកម្ពុជា ក្រុមហ៊ុនកម្ពុជារីបានបង្គរនូវចំណេះដឹងល្អៗ និងស្ថិតិស្តីអំពីប្រភេទ និងប្រវត្តិហានិភ័យនានានៅក្នុងទីផ្សារ។ ក្រុមហ៊ុនបានផ្តល់ជូននូវដំណោះស្រាយផ្ទេរហានិភ័យសមស្រប ដើម្បីរំលែកហានិភ័យនានា និងគាំទ្រវឌ្ឍនភាពអាជីវកម្មរបស់ក្រុមហ៊ុនធានារ៉ាប់រងដើម។

ក្រុមហ៊ុនបានផ្តល់ជូនសេវាកម្មធានារ៉ាប់រងបន្ត ដែលមានភាពទូលំទូលាយ និងប្រកួតប្រជែងលើគ្រប់ហានិភ័យទាំងធានារ៉ាប់រងទូទៅ និងអាយុជីវិតប្រកបដោយនវានុវត្តន៍ ប្រសិទ្ធភាព និងឆ្លើយតបតាមតម្រូវការ។ សេវាកម្មដែលផ្តល់តម្លៃបន្ថែមដល់ក្រុមហ៊ុន គឺផ្តោតលើការអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈធានារ៉ាប់រងក៏ដូចជាការកសាងប្រវត្តិហានិភ័យនានានៅក្នុងទីផ្សារត្រូវបានផ្តល់ជូនដោយក្រុមហ៊ុនធានារ៉ាប់រងទាំងអស់។

**៣.១.២ និមិត្តសញ្ញារបស់ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា កម្ពុជា រី**

ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា កម្ពុជា រីមាននិមិត្តសញ្ញាដូចខាងក្រោម៖

### ៣.១.៣ ការចាប់ដៃគូសហការ




ពិធីចុះហត្ថលេខាជាផ្លូវការលើកិច្ចព្រមព្រៀងធានារ៉ាប់រងបន្តរវាងក្រុមហ៊ុន អេហ្វដាប់ប៊ែលយូឌីឡាយហ្វ៍ អ៊ិនស្ទួរិន និងក្រុមហ៊ុនកម្ពុជា រីនៅព្រឹកថ្ងៃព្រហស្បតិ៍ ៨កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី ១១ ខែតុលា ឆ្នាំ២០២៤។ ក្រុមហ៊ុនអេហ្វដាប់ប៊ែលយូឌី ឡាយហ្វ៍ អ៊ិនស្ទួរិន និងក្រុមហ៊ុនកម្ពុជារី បានរៀបចំពិធីចុះហត្ថលេខាជាផ្លូវការលើកិច្ចព្រមព្រៀងធានារ៉ាប់រងបន្ត សម្រាប់ផលិតផលធានារ៉ាប់រងអាយុជីវិត។

ពិធីចុះហត្ថលេខានេះ ធ្វើឡើងក្នុងគោលបំណងនៃភាពជាដៃគូអាជីវកម្មដែលជាការគាំទ្រទីផ្សារធានារ៉ាប់រងកម្ពុជា ដើម្បីទទួលបានការការពារហិរញ្ញវត្ថុបន្ថែមទៀត។




ពិធីចុះហត្ថលេខាជាផ្លូវការលើកិច្ចព្រមព្រៀងធានារ៉ាប់រងបន្តរវាងក្រុមហ៊ុនហ្វ័រឈូន ឡាយហ្វ៍និងក្រុមហ៊ុនកម្ពុជា រី នៅព្រឹកថ្ងៃពុធ ៩កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១១ ខែកញ្ញា ឆ្នាំ

២០២៤។ ក្រុមហ៊ុន ហ្វ៊ូឈូនឡាយហ្វ៍ និងក្រុមហ៊ុន កម្ពុជារី បានរៀបចំពិធីចុះហត្ថលេខាជាផ្លូវការលើ **កិច្ចព្រមព្រៀងធានារ៉ាប់រងបន្ត** សម្រាប់ផលិតផលធានារ៉ាប់រងអាយុជីវិត។

ពិធីចុះហត្ថលេខានេះធ្វើឡើងក្នុងគោលបំណងនៃភាពជាដៃគូអាជីវកម្ម ដែលជាការគាំទ្រទីផ្សារធានារ៉ាប់រងកម្ពុជា ដើម្បីទទួលបានការការពារហិរញ្ញវត្ថុបន្ថែមទៀត។




ពិធីចុះហត្ថលេខាជាផ្លូវការលើកិច្ចព្រមព្រៀងធានារ៉ាប់រងបន្តរវាងក្រុមហ៊ុនដាយអ៊ីឈិឡាយហ្វ៍(ខេមបូឌា) និងក្រុមហ៊ុនកម្ពុជា រី។នៅព្រឹកថ្ងៃព្រហស្បតិ៍ ១១កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៤ ក្រុមហ៊ុន ដាយ អ៊ីឈិ ឡាយហ្វ៍ (ខេមបូឌា) និងក្រុមហ៊ុនកម្ពុជា រី បានរៀបចំពិធីចុះហត្ថលេខាជាផ្លូវការលើ **កិច្ចព្រមព្រៀងធានារ៉ាប់រងបន្ត** សម្រាប់ផលិតផលធានារ៉ាប់រងអាយុជីវិត។ ពិធីចុះហត្ថលេខានេះធ្វើឡើងក្នុងគោលបំណងនៃភាពជាដៃគូអាជីវកម្មដែលជា ការគាំទ្រទីផ្សារធានារ៉ាប់រងកម្ពុជាដើម្បីទទួលបានការការពារហិរញ្ញវត្ថុបន្ថែមទៀត។

### ៣.១.៤ បេសកកម្ម ទស្សនវិស័យ គុណតម្លៃ

- <u>**ចក្ខុវិស័យ**</u>

ជាដៃគូយុទ្ធសាស្ត្រក្នុងការផ្តល់ដំណោះស្រាយធានារ៉ាប់រងបន្តប្រកបដោយការពេញចិត្ត និងទំនុកចិត្ត។

- <u>**បេសកកម្ម**</u>
  - លើកកម្ពស់ការអភិវឌ្ឍឧស្សាហកម្មធានារ៉ាប់រង និងធានារ៉ាប់រងបន្ត និងវិជ្ជាជីវៈនិយម។
  - ផ្តល់នូវដំណោះស្រាយធានារ៉ាប់រងបន្តសមស្រប ទុកចិត្តបាន និងប្រកបដោយនវានុវត្តន៍។
  - ជាមជ្ឈមណ្ឌលសម្រាប់ប្រមូលផ្តុំ និងចែករំលែកទិន្នន័យអំពីហានិភ័យទីផ្សារ។
  - បង្កើនតម្លៃរបស់ភាគហ៊ុនិក និងអ្នកពាក់ព័ន្ធ រួមទាំងអតិថិជន ដៃគូអាជីវកម្ម និងនិយោជិត។
  - គាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍទីផ្សារធានារ៉ាប់រង និងការគ្រប់គ្រងហានិភ័យ នៅក្នុងប្រទេស រួមទាំងការកាត់បន្ថយលំហូរមូលធនទៅក្រៅប្រទេសដោយសារតែទីផ្សារក្នុងស្រុកមិនទាន់មានការអភិវឌ្ឍល្អ និងសមត្ថភាពរក្សាទុកបុព្វលាភមានកម្រិត។

- <u>គុណតម្លៃ</u>
  - ❖ **សុចរិតភាព៖** ក្រុមហ៊ុនប្រកបអាជីវកម្មប្រកបដោយឥរិយាបថវិជ្ជាជីវៈ និងក្រុមសីលធម៌ស្របតាមស្តង់ដារខ្ពស់បំផុត ដើម្បីជានាបាននូវកេរ្តិ៍ឈ្មោះ និងការជឿទុកចិត្តកម្រិតខ្ពស់។
  - ❖ **ការផ្តោតលើអតិថិជន៖** ក្រុមហ៊ុនមានការប្តេជ្ញាខ្ពស់ក្នុងការផ្តល់ជូនអតិថិជននូវដំណោះស្រាយប្រកបដោយប្រសិទ្ធភាព នវានុវត្តន៍ និងស្របតាមតម្រូវការ។
  - ❖ **កត្តាមនុស្ស៖** ក្រុមហ៊ុនមានមោទនភាពក្នុងការអភិវឌ្ឍធនធានមនុស្សក្នុងស្រុកឱ្យកាន់តែមានទេពកោសល្យខ្ពស់ ដោយបន្តលើកទឹកចិត្តពួកគេឱ្យស្ថិតនៅលើមាគ៌ានៃស្វ័យកែលម្អ និងភាពរីកចម្រើននៃអាជីព និងលើកកម្ពស់វប្បធម៌ភាពជាក្រុមហ៊ុនល្អដោយផ្សារភ្ជាប់ការលើកសរសើរទៅនឹងសមិទ្ធិផលរបស់បុគ្គល និងលទ្ធផលអាជីវកម្ម។
  - ❖ **កិច្ចសហការណ៍៖** ក្រុមហ៊ុនមានការប្តេជ្ញាខ្ពស់ ធ្វើការជិតស្និទ្ធជាមួយអ្នកពាក់ព័ន្ធនានាដើម្បីកំណើន និងការអភិវឌ្ឍប្រកបដោយចីរភាពនៃឧស្សាហកម្មធានារ៉ាប់រង។

**៣.១.៥ រចនាសម្ព័ន្ធរបស់ក្រុមហ៊ុន**



## ក្រុមប្រឹក្សាភិបាល

### ឯ. ឧ រស់ សីលវ៉ា

### ប្រធានក្រុមប្រឹក្សាភិបាល



ឯ.ឧ រស់ សីលវ៉ា ជាប្រធានក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន កម្ពុជារី តាំងពីឆ្នាំ២០១២មក។ ឯកឧត្តមបានរួមចំណែកយ៉ាងច្រើនដល់ការអភិវឌ្ឍក្រុមហ៊ុន ជាពិសេសការជួយធ្វើឱ្យកាន់តែប្រសើរឡើងនៃប្រព័ន្ធអភិបាលកិច្ច និងតម្រង់ទិសយុទ្ធសាស្ត្ររបស់ក្រុមហ៊ុន។ ឯកឧត្តមបានចូលបម្រើការងារនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅឆ្នាំ១៩៩៤ ហើយត្រូវបានដំឡើងតួនាទីជាហូរហែ រួមទាំងធ្លាប់ធ្វើជាទីប្រឹក្សាឱ្យនាយកប្រតិបត្តិរបស់ធនាគារពិភពលោក នៅទីស្នាក់ការកណ្តាលផងដែរ។ បច្ចុប្បន្នឯកឧត្តមជារដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាសមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិជាកន្លែងដែលឯកឧត្តមបានចូលរួមយ៉ាងសកម្មក្នុងការរៀបចំ និងដឹកនាំអនុវត្តគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសំខាន់ៗរបស់រាជរដ្ឋាភិបាលកម្ពុជា។ឯកឧត្តមទទួលបានសញ្ញាបត្របរិញ្ញបត្រវិទ្យាសាស្ត្រសង្គមមកពីវិទ្យាស្ថាន Penza’s Institute of Pedagogy អតីតសហភាពសូវៀតនិងសញ្ញាប័ត្របរិញ្ញាបត្រជាន់ខ្ពស់កិច្ចការអន្តរជាតិផ្នែកគ្រប់គ្រងគោលនយោបាយសេដ្ឋកិច្ចមកពីសាកលវិទ្យាល័យ កូឡុំប៊ី នៅក្នុងទីក្រុងញូយ៉ក សហរដ្ឋអាមេរិក។

### ឯ. ឧ ប៉ែន ពេជ្រសាលី

### សមាជិកក្រុមប្រឹក្សាភិបាល



ឯកឧត្តម ប៉ែន ពេជ្រសាលី លោកត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាលក្រុមហ៊ុនកម្ពុជារីនៅឆ្នាំ២០១៤។ឯកឧត្តមមានបទពិសោធន៍ក្នុងវិស័យច្បាប់នៅកម្ពុជារយៈពេលជាង២០ឆ្នាំមកហើយ។ បច្ចុប្បន្នឯកឧត្តមមានតួនាទីជាអគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌនៃក្រសួងយុត្តិធម៌ជាស្ថាប័នដែលគាត់ធ្វើការតាំងពីឆ្នាំ ១៩៩៥មក។ ឯកឧត្តមប៉ែន ពេជ្រសាលី ទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកច្បាប់ចំនួនពីរពីសាកលវិទ្យាល័យRussian Peoples’ Friendship University នៅឆ្នាំ១៩៩៥ និងពីសាកលវិទ្យាល័យ Nagoya នៅឆ្នាំ២០០២។

## លោក ធេឌី ហៃឡាំសាស
## សមាជិកក្រុមប្រឹក្សាភិបាល



លោក ធេឌី ហៃឡាំសាស ត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាលក្រុមហ៊ុនកម្ពុជារី តាំងពីឆ្នាំ២០០៤មកដែលជាតំណាងដៃគូភាគីយុទ្ធសាស្ត្រ។ គាត់មានបទពិសោធន៍ក្នុងវិស័យធានារ៉ាប់រងរយៈពេលជាង40ឆ្នាំមកហើយនៅប្រទេសឥណ្ឌូនេស៊ី។នៅក្នុងថ្នាក់តំបន់គាត់បានចូលរួមយ៉ាងសកម្ម ក្នុងសកម្មភាពរបស់ Asian Insurance Congress និង ASEAN Insurance Council ចាប់តាំងពីឆ្នាំ ១៩៩៩ មក។ លោកធេឌី ហៃឡាំសាសបានបញ្ចប់បរិញ្ញាបត្រពីមហាវិទ្យាល័យ South East Asia Union Colleges នៃប្រទេសសិង្ហបុរី។

## លោក យក់ ចំរើនឫទ្ធ
## សមាជិកក្រុមប្រឹក្សាភិបាល



លោក យក់ ចំរើនឫទ្ធិបានក្លាយជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនកម្ពុជារី ចាប់តាំងពីឆ្នាំ២០១៩ ហើយបច្ចុប្បន្នលោកក៏ជា ប្រធានអគ្គនាយកប្រតិបត្តិនៃក្រុមហ៊ុនធានារ៉ាប់រងហ្វតតេ (ខេមបូឌា) ភីអិលស៊ី ដែលមានភារៈទទួលខុសត្រូវលើការត្រួតពិនិត្យប្រតិបត្តិការទាំងមូល និងកំណត់ទិសដៅយុទ្ធសាស្ត្រសម្រាប់ គ្រប់ក្រុមហ៊ុនបុត្រសម្ពន្ធ័ទាំងអស់នៅក្នុងហ្វតតេគ្រុប។គាត់ក៏ជាសមាជិកក្រុមប្រឹក្សាភិបាលនៅក្នុងក្រុមហ៊ុនផ្សេង ផងដែរ។ លោក យក់ ចំរើនឫទ្ធិ មានបទពិសោធន៍ជំនាញជាង ២៥ ឆ្នាំលើផ្នែកធានារ៉ាប់រង ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ និងយុទ្ធសាស្ត្រ។ លោកទទួលបានអនុបណ្ឌិតពីសាកលវិទ្យាល័យ Charles Sturt ។ លោកក៏ទទួលបានសញ្ញាប័ត្រជាន់ខ្ពស់ផ្នែកធានារ៉ាប់រងពី វិទ្យាស្ថានធានារ៉ាប់រងម៉ាឡេស៊ី (FMII), Associate of Chartered Insurance Institute (ACII) ,and Senor Associate of Australian and New Zealand Institute of Insurance and Finance (ANZIIF) ។

## លោក ហ៊ុយ វ៉ាថារ៉ូ
## អគ្គនាយក និងជាសមាជិកក្រុមប្រឹក្សាភិបាល



លោកហ៊ុយវ៉ាថារ៉ូ ជាអគ្គនាយក និងសមាជិកក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនកម្ពុជារី ហើយក៏ជាប្រធានសមាគមធានារ៉ាប់រងកម្ពុជាតាំងពីឆ្នាំ ២០១៤ មក។ គាត់មានបទពិសោធន៍ជិត ២៥ឆ្នាំ ទាំងនៅក្នុងវិស័យសាធារណៈ ទាំងក្នុងវិស័យឯកជន ដែលមានបទពិសោធន៍ការងារទាំងផ្នែកវិស័យហិរញ្ញវត្ថុ និងវិស័យមិនមែនហិរញ្ញវត្ថុ។ គាត់បានចាប់ផ្តើមអាជីព ក្នុងវិស័យធានារ៉ាប់រងដោយបម្រើការនៅស្ថាប័ននិយ័តករធានារ៉ាប់រងនៅក្រោមក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ មុនការចូលរួមនៅក្នុងវិស័យធានារ៉ាប់រងគាត់បានរួមចំណែកជាច្រើននៅ ក្នុងដំណើរការបង្កើតទីផ្សារមូលបត្រជាលើកដំបូងនៅប្រទេសកម្ពុជា។ គាត់មានសញ្ញាបត្របរិញ្ញាបត្រវិទ្យាសាស្ត្រសេដ្ឋកិច្ច នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចនៅកម្ពុជា និងសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកអភិវឌ្ឍន៍អន្តរជាតិមកពីសាកលវិទ្យាល័យអន្តរជាតិជប៉ុននៃប្រទេសជប៉ុន។

## លោក រ័ត្ន វាសនា
## ប្រធានហិរញ្ញវត្ថុ និងសមាជិកក្រុមប្រឹក្សាភិបាល



លោក រ័ត្ន វាសនា បានចូលរួមជាមួយ ក្រុមហ៊ុន កម្ពុជារី នៅខែមេសា ឆ្នាំ២០០២ ក្នុងនាមជាប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ហើយលោកក៏ជាសមាជិកក្រុមប្រឹក្សាភិបាល (តំណាងនិយោជិក)។ ក្នុងកំឡុងរយៈពេល ១៨ ឆ្នាំ គាត់មានបទពិសោធន៍ និងចំណេះដឹងទូលទូលាយផ្នែកគណនេយ្យហិរញ្ញវត្ថុសម្រាប់វិស័យធានារ៉ាប់រង និងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។ លោកក៏បានចូលរួមចំណែកយ៉ាងសកម្ម ក្នុងតួនាទីស្នូលរបស់សមាគមធានារ៉ាប់រងកម្ពុជាក្នុងការដឹកនាំគណៈកម្មាធិការសំខាន់ៗ ដូចជាគណៈកម្មាធិការដោះស្រាយវិវាទ និងគណៈកម្មាធិការគណនេយ្យ និងជាតំណាងសមាគមធានារ៉ាប់រងនៅក្រុមប្រឹក្សាគណនេយ្យជាតិផងដែរ។ លោកបានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកសេដ្ឋកិច្ចពីសាកលវិទ្យាល័យ បច្ចេកវិទ្យា និងគ្រប់គ្រងនៅឆ្នាំ២០០៨ និងបានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនទាក់ទងនឹងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ (IFRS)។

## ៣.២ កាតព្វកិច្ចដែលអ្នកត្រូវបានធានាត្រូវបំពេញ ដើម្បីទទួលបានអត្ថប្រយោជន៍ពីក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជា រី"

### ៣.២.១ ការចុះកិច្ចសន្យាធានារ៉ាប់រង

ការធានារ៉ាប់រងដែលមានប្រយោជន៍ដល់អ្នកត្រូវបានធានាចំពោះហានិភ័យទាំងឡាយ ត្រូវតែជាការចុះកិច្ចសន្យាធានារ៉ាប់រងជាមួយក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជា រី" ដែលមានអាជ្ញាបណ្ណឱ្យធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្នុងការធ្វើកិច្ចសន្យាធានារ៉ាប់រង អ្នកត្រូវបានធានារ៉ាប់រង និងក្រុមហ៊ុនធានារ៉ាប់រងត្រូវគោរពតាម គោលការណ៍ស្មោះត្រង់ដែលមានផលប្រយោជន៍ទៅវិញទៅមកមានការស្រុះស្រួលគ្នាដោយឆ្លងតាមការចរចា និងមិនធ្វើឱ្យប៉ះពាល់ផលប្រយោជន៍សាធារណៈឡើយ។ ចំពោះកិច្ចសន្យាធានារ៉ាប់រងមានធាតុជាអប្បបរមាដូចជា បណ្ណសន្យារ៉ាប់រង និងវិញ្ញាបនបត្រធានារ៉ាប់រង។

### ៣.២.២ កាតព្វកិច្ចដែលអ្នកត្រូវបានធានាត្រូវបំពេញ

ដើម្បីទទួលបានអត្ថប្រយោជន៍ពេញលេញពីក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជា រី" អ្នកត្រូវបានធានាចាំបាច់ត្រូវតែបំពេញកាតព្វកិច្ចមួយចំនួន ដែលពាក់ព័ន្ធនឹងការកើតឡើងនូវហានិភ័យធានារ៉ាប់រងដែលបានកំណត់ជាជម្រើស ឬជាលក្ខខណ្ឌក្នុងកិច្ចសន្យាធានារ៉ាប់រងបន្ត។ អ្នកដែលមានបំណងចង់ទទួលបានអត្ថប្រយោជន៍ពីក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជា រី" ត្រូវមានភាពសកម្ម និងប្រកាន់ខ្ជាប់ក្នុងការបំពេញកាតព្វកិច្ចខាងក្រោមនេះដើម្បីធានាថាសិទ្ធិនៃការទទួលសំណងត្រូវបានរក្សា និងអនុវត្តតាមច្បាប់និងបទបញ្ជារបស់ក្រុមហ៊ុន៖

- ផ្តល់ព័ត៌មានផ្ទាល់មាត់ និងឯកសារលាយលក្ខណ៍អក្សរដោយពិស្តារ ច្បាស់លាស់ប្រកបដោយភាពស្មោះត្រង់ទៅឱ្យក្រុមហ៊ុនធានារ៉ាប់រង
- កាតព្វកិច្ចបង់បុព្វលាភធានារ៉ាប់រង៖ បន្ទាប់ពីធ្វើកិច្ចសន្យាធានារ៉ាប់រងរួចហើយ អ្នកត្រូវបានធានារ៉ាប់រងត្រូវបង់បុព្វលាភធានារ៉ាប់រងជូនក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា " កម្ពុជា រី" គ្រប់ចំនួនតាមការព្រមព្រៀងគ្នាតាមកិច្ចសន្យា។ ការបង់បុព្វលាភរ៉ាប់រងចំពោះហានិភ័យណាមួយ គឺជាកាតព្វកិច្ចទីមួយរបស់អ្នកត្រូវបានធានារ៉ាប់រង។ បុព្វលាភរ៉ាប់រងត្រូវបង់ឱ្យបានត្រឹមត្រូវតាមរយៈពេលធានា និងតាមចំនួនទឹកប្រាក់ធានារ៉ាប់រងសរុប ដោយគិតផ្អែកលើមូលដ្ឋាននៃតារាងបុព្វលាភរ៉ាប់រងរបស់ក្រុមហ៊ុននីមួយៗ។ ក្នុងការបង់បុព្វលាភរ៉ាប់រង អ្នកត្រូវបានធានារ៉ាប់រងអាចពិភាក្សាហើយព្រមព្រៀងជាមួយក្រុមហ៊ុនធានារ៉ាប់រង ដើម្បីធ្វើការបង់តែមួយលើក ឬច្រើនលើកបាន។
- កាតព្វកិច្ចក្នុងការជូនដំណឹង៖ អ្នកត្រូវបានធានាត្រូវជូនដំណឹង ឬផ្តល់ភស្តុតាងដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរជូនដល់ក្រុមហ៊ុនធានារ៉ាប់រងបន្តឱ្យបានឆាប់រហ័ស ឬសមស្របទៅតាមកិច្ចសន្យាធានារ៉ាប់រងពាក់ព័ន្ធនឹងការកើតឡើងនូវហានិភ័យធានារ៉ាប់រង ដើម្បីឱ្យក្រុមហ៊ុនកម្ពុជារីប្រើប្រាស់ជាមូលដ្ឋាននៅក្នុងការសិក្សា វាយតម្លៃមុននឹងកំណត់ និងទូទាត់សំណង។ ក្រុម

ហ៊ុនកម្ពុជារ៉េ អាចពន្យាពេលក្នុងការចាប់ផ្តើមនីតិវិធីកំណត់ និងទូទាត់សំណងបានករណី អ្នកត្រូវបានធានាជូនផ្តល់ព័ត៌មានមិនទាន់ពេលវេលា។

## ៣.៣ អត្ថប្រយោជន៍ដែលទទួលបានពីក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា កម្ពុជា រ៉េ

### ៣.៣.១ ផលិតផលនិងការគាំទ្រ

ក្រុមហ៊ុន កម្ពុជារ៉េ ផ្តល់ការគាំទ្រនូវសមត្ថភាពធានារ៉ាប់រងបន្តនៃហានិភ័យផ្សេងៗក្នុងទម្រង់ជា សន្ធិសញ្ញាធានារ៉ាប់រងបន្ត (Treaty) និងធានារ៉ាប់រងបន្ត Facultative លើគ្រប់ផ្នែកនៃធានារ៉ាប់រង រួមមាន ធានារ៉ាប់រងទូទៅ ធានារ៉ាប់រងអាយុជីវិត និងធានារ៉ាប់រងខ្នាតតូច។

ក្រុមហ៊ុន ទទួលយកគ្រប់ប្រភេទហានិភ័យនៃអាជីវកម្មធានារ៉ាប់រងទូទៅ មានដូចជា អគ្គីភ័យ យានយន្ត សុខភាព វិស្វកម្ម ការដឹកជញ្ជូន និង គ្រោះថ្នាក់ផ្សេងៗ។

ក្រុមហ៊ុន ផ្តល់ដំណោះស្រាយធានារ៉ាប់រងបន្តអាយុជីវិត លើហានិភ័យមរណភាព (Mortality) និងជម្ងឺផ្សេងៗ(Morbidity) សម្រាប់ប្រភេទផលិតផលធានារ៉ាប់រងអាយុជីវិតនានា រួមមាន ធានារ៉ាប់រងអាយុជីវិតជាក្រុម ធានារ៉ាប់រងអាយុជីវិតជាបុគ្គល គ្រោះថ្នាក់ និង សុខភាព ។ល។

បន្ថែមលើការធានារ៉ាប់រងបន្តដែលជាអាជីវកម្មស្នូល ក្រុមហ៊ុនកម្ពុជារ៉េ ផ្តល់នូវសេវាតម្លៃបន្ថែមមួយចំនួនទៀត ដើម្បីគាំទ្រអតិថជនក៏ដូចជាទីផ្សារធានារ៉ាប់រងទាំងមូលដូចខាងក្រោម ៖

ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ៖ យើងជឿជាក់ថាការអប់រំជាប្រចាំ (on-going education) ជាកត្តាសំខាន់ដើម្បីដើរទាន់ការវិវត្តនៃទីផ្សារ និងបំពាក់បំប៉នកម្រិតវិជ្ជាជីវៈរបស់បុគ្គលិក ។ ក្រុមហ៊ុនកម្ពុជារ៉េមានកិច្ចសហការជាមួយគ្រឹះស្ថានផ្តល់ការអប់រំធានារ៉ាប់រង ក្នុងការរៀបចំវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាផ្សេងៗលើប្រធានបទទាក់ទងនឹងធានារ៉ាប់រង សម្រាប់បុគ្គលិកជំនាញវិជ្ជាជីវៈ ។

ប្រភេទ និងប្រវត្តិហានិភ័យក្នុងទីផ្សារ៖ ទិន្នន័យគ្រប់គ្រាន់ (sufficient data) ពិតជាមានសារៈសំខាន់សម្រាប់អាជីវកម្មធានារ៉ាប់រង និងធានារ៉ាប់រងបន្ត។ នេះជាមូលហេតុដែលក្រុមហ៊ុនកម្ពុជារ៉េ បានពង្រឹងតួនាទីរបស់ខ្លួនក្នុងការបង្កើត និងគ្រប់គ្រងមូលដ្ឋានទិន្នន័យដែលមានស្ថិតិទិន្នន័យទូលំទូលាយសម្រាប់ក្រុមហ៊ុនធានារ៉ាប់រងប្រើប្រាស់ក្នុងការផ្តល់សេវាកម្មដល់ទីផ្សារ និងគ្រប់គ្រងប្រតិបត្តិការអាជីវកម្មរបស់ពួកគេឱ្យកាន់តែត្រឹមត្រូវ និងមានប្រសិទ្ធភាព។

សកម្មភាពគាំទ្រវិស័យធានារ៉ាប់រង៖ ក្រុមហ៊ុនធានារ៉ាប់រងកម្ពុជា "កម្ពុជារ៉េ"បានដើរតួនាទីយ៉ាងសកម្មក្នុងការគាំទ្រសកម្មភាពនានារបស់សមាគមធានារ៉ាប់រងកម្ពុជារួមមានដូចជា ការដឹកនាំក្រុមការងារនានារបស់សមាគមន៍ដូចជាគណៈកម្មការអគ្រាបុព្វលាភធានារ៉ាប់រងអគ្គីភ័យ និងគណៈកម្មការដោះស្រាយសំណងធានារ៉ាប់រងយានយន្ត ដើម្បីធានាការប្រកួតប្រជែងដោយស្មើភាពក្នុងចំណោមសមាជិកក៏ដូចជាដើម្បីការពារផលប្រយោជន៍របស់អ្នកប្រើប្រាស់ធានារ៉ាប់រង។

### ៣.៣.២ ស្ថានភាពទីផ្សារ

ស្ថានភាពទីផ្សាររបស់ក្រុមហ៊ុនធានារ៉ាប់រង កម្ពុជារ៉េ គឺមានលក្ខណៈ ល្អគ្រប់គ្រាន់ហើយពីព្រោះអតិថិជនមានការទទួលស្គាល់ច្រើន ហើយក្រុមហ៊ុនក៏បានខិតខំប្រឹងប្រែងប្រែង ស្វែងរកមធ្យោបាយផ្សេងទៀត ដើម្បីពង្រីក

ទីផ្សាររបស់ខ្លួនឱ្យកាន់តែរីកលូតលាស់បន្ថែមទៀត។ ក្រុមហ៊ុនកម្ពុជារ៉េ គឺជាក្រុមហ៊ុនធានារ៉ាប់រងបន្តតែមួយគត់នៅកម្ពុជា ព្រោះតែការយកចិត្តទុកដាក់ និងផ្តល់ទំនុកចិត្តដល់អតិថិជនទើបធ្វើឱ្យក្រុមហ៊ុនកម្ពុជារ៉េមានដៃគូសហការច្រើន ជាហេតុដែលធ្វើឱ្យវិស័យធានារ៉ាប់រងកាន់តែរីកចម្រើនច្រើន និងជួយដោះស្រាយនូវហានិភ័យផ្សេងៗជូនអតិថិជនបានកាន់តែច្រើនបន្ថែមទៀត។

**៣.៣.៣ ការវាយតម្លៃលើស្ថានភាពទីផ្សារ**

ក្រុមហ៊ុនធានារ៉ាប់រង កម្ពុជារ៉េ គឺជាក្រុមហ៊ុនធានារ៉ាប់រងក្នុងស្រុកដែលមានតួនាទីសំខាន់ក្នុងទីផ្សារធានារ៉ាប់រងនៅកម្ពុជា។ ក្រុមហ៊ុននេះផ្តល់សេវាកម្មធានារ៉ាប់រងជាច្រើនប្រភេទ ដូចជា ធានារ៉ាប់រងជីវិត ធានារ៉ាប់រង សុខភាព និងធានារ៉ាប់រងទ្រព្យសម្បត្តិ។ ក្នុងបរិបទទីផ្សារធានារ៉ាប់រង កម្ពុជាកំពុងរីក ចម្រើនកម្ពុជារ៉េបានព្យាយាម កែលម្អសេវាកម្មរបស់ខ្លួន ដើម្បីបំពេញតម្រូវការរបស់អតិថិជន។ ក្រុមហ៊ុនបានផ្តោតលើការផ្តល់សេវាកម្មដែលមានគុណភាព និងការឆ្លើយតបរហ័សដល់អតិថិជន។ ដើម្បីរក្សាការឈានមុខ កម្ពុជារ៉េត្រូវបន្តកែលម្អសេវាកម្ម និងបង្កើនការយល់ដឹងរបស់សាធារណជនអំពីអត្ថប្រយោជន៍នៃការធានារ៉ាប់រង។

សរុបមក កម្ពុជារ៉េមានស្ថានភាពទីផ្សារល្អ ប៉ុន្តែក៏នៅត្រូវការការបន្តកែលម្អ និងការលើកស្ទួយដើម្បីដោះស្រាយបញ្ហានានា និងបង្កើនការចូលរួមរបស់ប្រជាជននៅក្នុងវិស័យធានារ៉ាប់រង។ ជាក់ស្តែងក្នុងកំឡុងឆ្នាំ2019 ក្រុមហ៊ុនកម្ពុជារ៉េបានទទួលពានរង្វាន់ចំនួនពីរគឺ៖

- ❖ ពានរង្វាន់ **Best Education and Training Provider-Insurance ( Cambodia )** **និង** **Best Customer Centric Reinsurance Company ( Cambodia )** ពីស្ថាប័ន International finance


INTERNATIONAL FINANCE

INTERNATIONAL FINANCE AWARDS 2019

This is to certify that

Cambodian Reinsurance Company "Cambodia Re"

Has been awarded

Best Education and Training Provider - Insurance

Cambodia

International Finance Publications Ltd.

Sunil Bhat, Director International Finance


INTERNATIONAL FINANCE

INTERNATIONAL FINANCE AWARDS 2019

This is to certify that

Cambodian Reinsurance Company "Cambodia Re"

Has been awarded

Best Customer Centric Reinsurance Company

Cambodia

International Finance Publications Ltd.

Sunil Bhat, Director International Finance

### ៣.៣.៤ អត្ថប្រយោជន៍នៃការប្រើប្រាស់សេវាធានារ៉ាប់រងបន្តរបស់កម្ពុជារី

ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា កម្ពុជារីផ្តល់សេវាធានារ៉ាប់រងបន្ត និងអត្ថប្រយោជន៍ផ្សេងទៀតដល់ឧស្សាហកម្មធានារ៉ាប់រងនៅកម្ពុជា។ អត្ថប្រយោជន៍ទាំងនេះរួមមានៈ

- ការផ្ទេរហានិភ័យៈ សេវាធានារ៉ាប់រងបន្តអនុញ្ញាតឱ្យក្រុមហ៊ុនធានារ៉ាប់រងដើម អាចផ្ទេរបន្តនូវហានិភ័យដែលពួកគេមិនអាចគ្រប់គ្រងបានប្រគល់ទៅកាន់ក្រុមហ៊ុនកម្ពុជារី។ វាជារបៀបសំខាន់មួយក្នុងការធានាបាននូវស្ថិរភាពហិរញ្ញវត្ថុពេលមានហេតុអាសន្នធំៗ។ ជាឧទាហរណ៍ នៅពេលមានគ្រោះធម្មជាតិដូចជា ភ្លៀងធ្លាក់ខ្លាំង បណ្តាលឱ្យមានទឹកជំនន់ កម្ពុជានឹងជួយទទួលខុសត្រូវជំនួសផ្នែកមួយក្នុងការសងប្រាក់សំណងទៅកាន់អតិថិជន។
- ការពង្រីកសមត្ថភាពៈ តាមធម្មតាក្រុមហ៊ុនធានារ៉ាប់រងមួយមានកម្រិតក្នុងការធានាឱ្យហានិភ័យធំៗដោយសារតែទុនផ្ទាល់មិនគ្រប់គ្រាន់។ ការចូលរួមជាមួយក្រុមហ៊ុន កម្ពុជារី អនុញ្ញាតឱ្យពួកគេចូលរួមធានាឱ្យគម្រោងធំៗ ឬអតិថិជនដែលត្រូវការអត្ថប្រយោជន៍ជាច្រើន។ នេះជួយបង្កើនអាជីវកម្ម និងការប្រកួតប្រជែងក្នុងទីផ្សារ។
- ការការពារគ្រោះមហន្តរាយៈ កម្ពុជារី ផ្តល់ការការពារបន្ថែមក្នុងករណីមានគ្រោះធម្មជាតិ ឬគ្រោះអាសន្នធំៗ។ ការការពារនេះជួយរក្សាស្ថិរភាពរបស់ប្រព័ន្ធហិរញ្ញវត្ថុនៃក្រុមហ៊ុនធានារ៉ាប់រងដើម ហើយជាប្រយោជន៍សំខាន់សម្រាប់ប្រទេសមួយដែលមានហានិភ័យ។ ការមានការការពារជានិច្ចអាចជួយឱ្យអតិថិជនទទួលបានសំណងបានទាន់ពេលវេលា និងពេញលេញ។
- ការសង្គ្រោះដើមទុនៈ ក្រុមហ៊ុនធានារ៉ាប់រងត្រូវរក្សាទុនដើម្បីធានាការប្រឈមហានិភ័យ។ តែដោយសារការបន្តការធានារ៉ាប់រងទៅកាន់ កម្ពុជារី ក្រុមហ៊ុនដើមអាចកាត់បន្ថយបន្ទុកលើទុននោះ ហើយប្រើប្រាស់ទុនសំរាប់ការវិនិយោគ ឬការអភិវឌ្ឍផលិតផលថ្មី។ នេះជួយបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ទុន និងការប្រកួតប្រជែង។
- ការអភិវឌ្ឍវិជ្ជាជីវៈៈ កម្ពុជារី មិនត្រឹមតែផ្តល់សេវាបន្តទេ ប៉ុន្តែបង្ហាញខ្លួនជាដៃគូអាជីពដោយផ្តល់ការបណ្តុះបណ្តាល បច្ចេកទេស និងការគាំទ្រផ្នែកសិក្សាហានិភ័យ។ វាជួយឱ្យបុគ្គលិកក្រុមហ៊ុនធានារ៉ាប់រងក្នុងស្រុកកើនឡើងជំនាញ វិជ្ជាជីវៈ និងការយល់ដឹងអំពីបច្ចេកទេសអន្តរជាតិ។
- ទម្រង់ហានិភ័យទីផ្សារៈ កម្ពុជារី អាចជួយក្រុមហ៊ុនធានារ៉ាប់រងដើមចែកចាយហានិភ័យនៅក្នុងវិស័យផ្សេងៗដូចជា សុខភាព អចលនទ្រព្យ ឬឧស្សាហកម្មធុនធំ។ វាជួយកាត់បន្ថយហានិភ័យនៅក្នុងវិស័យតែមួយដោយធ្វើឱ្យប្រព័ន្ធសេដ្ឋកិច្ចធានារ៉ាប់រង មានភាពប្រក្រតីនិងអាចទប់ទល់នឹងការផ្លាស់ប្តូរផ្សេងៗបាន។
- ការគាំទ្រផ្នែកឧស្សាហកម្មៈ មានតួនាទីសំខាន់ក្នុងការគាំទ្រនិងលើកកម្ពស់វិស័យធានារ៉ាប់រងក្នុងស្រុក។ កម្ពុជារីធ្វើការចូលរួមជាមួយនឹងក្រសួងសេដ្ឋកិច្ច ការបណ្តុះបណ្តាល ការចូលរួមផ្តល់យោបល់លើនីតិវិធី និងការអភិវឌ្ឍគោលនយោបាយដើម្បីធានាឱ្យវិស័យធានារ៉ាប់រងមានស្ថិរភាព និងការលូតលាស់ប្រកបដោយចីរភាព។

**៣.៣.៥ ការចូលរួមអភិវឌ្ឍ**

បន្ថែមលើការធានារ៉ាប់រងបន្តដែលជាអាជីវកម្មស្នូល ក្រុមហ៊ុនកម្ពុជារីផ្តល់នូវសេវាតម្លៃបន្ថែមមួយចំនួនទៀត ដើម្បីគាំទ្រអតិថិជនក៏ដូចជាទីផ្សារធានារ៉ាប់រងទាំងមូលដូចខាងក្រោម ៖

**ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ៖** យើងជឿជាក់ថាការអប់រំជាប្រចាំ (on-going education) ជាកត្តាសំខាន់ដើម្បីដើរទាន់ការវិវត្តនៃទីផ្សារ និងបំពាក់បំប៉នកម្រិតវិជ្ជាជីវៈរបស់បុគ្គលិក។ក្រុមហ៊ុនកម្ពុជារី មានកិច្ចសហការជាមួយគ្រឹះស្ថានផ្តល់ការអប់រំធានារ៉ាប់រង ក្នុងការរៀបចំវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាផ្សេងៗលើប្រធានបទទាក់ទងនឹងធានារ៉ាប់រង សម្រាប់បុគ្គលិកជំនាញវិជ្ជាជីវៈ ។

**ការចូលរួមអភិវឌ្ឍសង្គម៖** ក្រុមហ៊ុន កម្ពុជារី មានមោទនភាពក្នុងការរួមចំណែកដល់អនាគតនៃសហគមន៍របស់យើង តាមរយៈការឧបត្ថម្ភជាសម្ភារៈសិក្សា និងផ្តល់ជំនួយហិរញ្ញវត្ថុមួយចំនួនសម្រាប់ការជួសជុលសាលារៀន នៅសាលាបឋមសិក្សាជ្រៃអណ្តែត ស្ថិតនៅភូមិព្រែកតាព្រហ្ម ឃុំកំពង់អុស ស្រុកពញាឮ ខេត្តកណ្តាល។ ការអប់រំ គឺជាមូលដ្ឋានគ្រឹះសម្រាប់អនាគតដ៏ភ្លឺស្វាងហើយក្រុមហ៊ុនកម្ពុជារីនៅតែបន្តផ្តល់ការគាំទ្រដល់មនុស្សជំនាន់ក្រោយតាមរយៈគំនិតផ្តួចផ្តើមនូវសកម្មភាពទទួលខុសត្រូវខាងសង្គមរបស់យើង។ យើងរួមគ្នាកសាងប្រទេសកម្ពុជាឱ្យកាន់តែរឹងមាំ និងមានការអប់រំកាន់តែច្រើន។

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

## ៤.១ ការវិភាគលើចំណុចខ្លាំង

ចំណុចខ្លាំងនៃការធានារ៉ាប់រងបន្តរបស់ក្រុមហ៊ុនកម្ពុជា"កម្ពុជារេ"មានដូចជា៖

- **ការទទួលបានការការពារហានិភ័យលើសសមត្ថភាព៖** ក្រុមហ៊ុនកម្ពុជារេមានតួនាទីសំខាន់ក្នុងការទទួលបន្តហានិភ័យ ពីក្រុមហ៊ុនធានារ៉ាប់រងដើម។ វាជួយឱ្យក្រុមហ៊ុនដើមអាចទទួលខុសត្រូវលើហានិភ័យធំៗ ដូចជាគ្រោះថ្នាក់ធម្មជាតិ ឬគ្រោះអគ្គីភ័យដែលមានថ្លៃសងខ្ពស់។ ដោយសារតែមានក្រុមហ៊ុនកម្ពុជារេ ជាអ្នកគាំទ្រទើបក្រុមហ៊ុនដើមមានទំនុកចិត្តក្នុងការទទួលការធានាជាច្រើនប្រភេទ និងក្នុងចំនួនធំៗ។
- **ធានាបាននូវសមត្ថភាពសងប្រាក់ខ្ពស់ក្នុងករណីខូចខាតធំៗ៖** ដោយសារតែមាន ក្រុមហ៊ុនធានារ៉ាប់រងកម្ពុជារេ ជាភ្នាក់ងារបន្ត ក្រុមហ៊ុនធានារ៉ាប់រងដើមមានសមត្ថភាពបន្ថែមក្នុងការសងប្រាក់ អតិថិជនទទួលបានការសងប្រាក់តាមសិទ្ធិពេញលេញ។
- **បង្កើនការជឿជាក់ជូនអតិថិជន៖** ការដែលអតិថិជនដឹងថាមានក្រុមហ៊ុនកម្ពុជារេជាអ្នកធានាជាអ្នកគាំទ្រក្រោយក្រុមហ៊ុនដើម គឺជាជំនួយក្នុងការបង្កើនទំនុកចិត្ត និងជ្រើសរើសប្រើសេវាកម្ម។
- **ជួយបណ្តុះបណ្តាល និងគាំទ្រផ្នែកបច្ចេកទេស៖** ក្រុមហ៊ុន កម្ពុជារេ មិនត្រឹមតែផ្តល់ជាការគាំទ្រហិរញ្ញវត្ថុប៉ុណ្ណោះទេ ប៉ុន្តែអាចផ្តល់ជំនួយបច្ចេកទេសដល់ក្រុមហ៊ុនដើម ក្នុងការវាយតម្លៃហានិភ័យ ការគ្រប់គ្រងបញ្ហា និងការអភិវឌ្ឍផលិតផល។ ផលិតផលធានារ៉ាប់រងមានគុណភាព និងឆ្លើយតបតាមតម្រូវការរបស់អតិថិជន។

ក្នុងនាមជាក្រុមហ៊ុនផ្តល់សេវាកម្មដល់អតិថិជនដែលជានីតិបុគ្គល(ក្រុមហ៊ុនឬសគ្រាសផ្សេងៗ)ក្រុមហ៊ុនកម្ពុជារេ នៅតែអាចផ្តល់នូវសេវាកម្មរហ័សទាន់ចិត្ត ជាពិសេសនៅពេលមានការថ្លោះធ្លោយកំឡុងពេលផ្តល់សេវាកម្ម ឬការផ្តល់សេវាកម្មរួចហើយក៏ដោយ ក៏ក្រុមហ៊ុននៅតែចេញមុខដោះស្រាយ ជូនដល់អតិថិជនរបស់ខ្លួនដែរ។

## ៤.២ ចំណុចខ្សោយ

ចំណុចខ្សោយនៃការធានារ៉ាប់រងបន្តរបស់ក្រុមហ៊ុនកម្ពុជា "កម្ពុជារេ" មានដូចជា៖

- **អតិថិជនមិនទាន់យល់អំពីតួនាទីរបស់ក្រុមហ៊ុនកម្ពុជារេ៖** ដោយសារតែកម្ពុជារេ មិនទាក់ទងផ្ទាល់ជាមួយអតិថិជន ដូច្នេះអ្នកប្រើប្រាស់ជារឿយៗមិនដឹងថា ការសងប្រាក់ ឬការគ្រប់គ្រងហានិភ័យខ្លះៗមានការជួយពី ក្រុមហ៊ុនកម្ពុជារេ ។ ដោយសារតែភាព"នៅខាងក្រោយ"នេះបណ្តាលឱ្យអតិថិជនមិនយល់ពីអត្ថប្រយោជន៍ដែលខ្លួនទទួលបានពីកម្ពុជារេ ។
- **សមត្ថភាពហិរញ្ញវត្ថុ និងបច្ចេកទេសនៅមានកម្រិតកំណត់៖** បើប្រៀបធៀប កម្ពុជារេ ជាមួយក្រុមហ៊ុនធានារ៉ាប់រងបន្តអន្តរជាតិ វាអាចមានកម្រិតហិរញ្ញវត្ថុ និងបច្ចេកទេសមិនទាន់សមរម្យក្នុងករណីហានិភ័យធ្ងន់ៗ។ នេះអាចប៉ះពាល់ដល់សមត្ថភាពបង្កើតអត្ថប្រយោជន៍ឱ្យអតិថិជន ជាពិសេសពេលមានហានិភ័យដ៏ធំ។

- **ការអភិវឌ្ឍផលិតផលថ្មីនៅតិច៖** កម្ពុជាវីផ្តោតតែទៅលើការជានាបន្តតែប៉ុណ្ណោះ ដោយមិនមានផលិតផលថ្មីៗដែលផ្តល់អត្ថប្រយោជន៍ផ្ទាល់ទៅអតិថិជន។ ដូចនេះហើយ អត្ថប្រយោជន៍ផ្ទាល់របស់អតិថិជនគឺ មានកម្រិតតិច និងមិនសូវច្បាស់។
- **ភាពពឹងផ្អែកលើក្រុមហ៊ុនធានារ៉ាប់រងដើម៖** ក្រុមហ៊ុនកម្ពុជាវីពឹងផ្អែកលើក្រុមហ៊ុនដើមក្នុងការបញ្ជូនហានិភ័យ។ប្រសិនបើក្រុមហ៊ុនដើមមិនសកម្ម ឬក៏មិនពង្រឹងសេវារបស់ខ្លួនទេ កម្ពុជាវី ក៏នឹងមិនអាចបញ្ចេញអត្ថប្រយោជន៍បានច្រើនដែរ។ អតិថិជននឹងមិនទទួលអត្ថប្រយោជន៍ពេញលេញប្រសិនបើក្រុមហ៊ុនដើមមិនយកចិត្តទុកដាក់។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

តាមរយៈលទ្ធផលនៃការស្រាវជ្រាវ ព្រមទាំងបានធ្វើការស្វែងយល់អំពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា កម្ពុជារី ក្រោមប្រធានបទ "អត្ថប្រយោជន៍ដែលទទួលបានពីក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា កម្ពុជា រី" ក្រុមនាងខ្ញុំអាចសន្និដ្ឋានបានថាការការធានារ៉ាប់រងបន្ត មានភាពងាយស្រួល និងមានប្រសិទ្ធិភាព ព្រោះថា ក្រុមហ៊ុនមាននូវទំនួលខុសត្រូវក្នុងការជួយចេញសំណងលើគ្រប់ប្រភេទនៃហានិភ័យបានល្អហើយបានទាន់ពេលវេលា ក្រុមហ៊ុនមានការយកចិត្តទុកដាក់ខ្ពស់ចំពោះអតិថិជនក៏ដូចជាដៃគូសហការ និងផ្តល់ការការពារក្រុមហ៊ុនដែលបានទិញសេវាកម្មធានារ៉ាប់រងកុំឱ្យក្ស័យធន ការកាត់បន្ថយនូវបន្ទុកហានិភ័យ ផ្តល់ស្ថិរភាពហិរញ្ញវត្ថុដែលធ្វើឱ្យដៃគូសហការមានទំនុកចិត្តប្រកបដោយស្នាមញញឹមព្រមទាំងទទួលបាននូវពានរង្វាន់ជាច្រើនផងដែរ។ លើសពីនេះទៀតសេវាធានារ៉ាប់រងបន្តរបស់ កម្ពុជារី បានជួយឱ្យវិស័យធានារ៉ាប់រងនៅប្រទេសកម្ពុជាកាន់តែមានភាពរីកចម្រើន ដោយសារការជឿទុកចិត្ត។ សេវាធានារ៉ាប់រងបន្តជួយពង្រឹងសុវត្ថិភាពហិរញ្ញវត្ថុសម្រាប់ប្រជាជន។ ជារួមវាជាឧបករណ៍សំខាន់មួយដែលរួមចំណែកក្នុងការជំរុញការរីកចម្រើនសេដ្ឋកិច្ច និងធានាបាននូវភាពជាប់លាប់ក្នុងជីវភាពសង្គម។

ដោយឡែក ការយល់ដឹងរបស់អតិថិជនអំពីតួនាទី និងអត្ថប្រយោជន៍របស់ក្រុមហ៊ុនកម្ពុជារីនៅមានកម្រិតខ្ពស់បន្តិច។ ដូចនេះការផ្សព្វផ្សាយ និងការអភិវឌ្ឍផលិតផលថ្មីៗអាចជាជំហានសំខាន់សម្រាប់បង្កើនតម្លៃ និងសមត្ថភាពប្រកួតប្រជែងរបស់ក្រុមហ៊ុននៅពេលអនាគត។

## ៥.២ ការផ្តល់អនុសាសន៍

ថ្វីត្បិតតែថាក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា កម្ពុជារីមានការរីកចម្រើន ព្រមទាំងមានវិធីសាស្ត្រ និងការផ្តល់សំណងដល់អតិថិជនល្អដ៏ពិតមែន ប៉ុន្តែក្រុមហ៊ុននៅតែមាននូវចំណុចខ្វះខាតមួយចំនួនដែលមិនបានគិតគូ ឬអាចមើលរំលងនូវចំណុចខ្វះខាតទាំងនោះដែលធ្វើឱ្យរាំងស្ទះដល់ការងារក្រុមហ៊ុន និងខាតបង់ប្រយោជន៍រួមទាំងធ្វើឱ្យមានការប៉ះពាល់ដល់ទំនុកចិត្តរបស់អតិថិជនផងដែរ។

- **បង្កើនការផ្សព្វផ្សាយអប់រំសាធារណៈ៖** បង្កើតកម្មវិធីផ្សព្វផ្សាយឬជាសិក្ខាសាលាដើម្បីណែនាំពន្យល់អំពីតួនាទី និងអត្ថប្រយោជន៍របស់កម្ពុជារីក្នុងប្រព័ន្ធធានារ៉ាប់រងផ្សព្វផ្សាយ តាមរយៈបណ្តាញសង្គមឱ្យប្រជាជនស្គាល់កាន់តែច្បាស់ពីសេវាធានារ៉ាប់រងបន្តរបស់កម្ពុជារី។
- **បង្កើនសមត្ថភាពហិរញ្ញវត្ថុ និងបច្ចេកទេស៖** រកមូលនិធិបន្ថែម តាមរយៈកិច្ចសហការជាមួយភាគីរដ្ឋនិងឯកជន ផ្តោតលើការចូលបណ្តាញអន្តរជាតិក្នុងវិស័យ Reinsurance ដើម្បីយកបទពិសោធន៍និងបច្ចេកវិទ្យាទំនើប។

- **អភិវឌ្ឍផលិតផលថ្មីឱ្យទាក់ទងជាមួយអតិថិជនផ្ទាល់៖** ទោះបីជាកម្ពុជារីជាក្រុមហ៊ុនបន្តក៏ដោយ ក៏គួរបង្កើតគម្រោងឬសេវាផ្សេងៗដែលអាចបង្កើនអត្ថប្រយោជន៍ផ្ទាល់ទៅអតិថិជន (ដូចជាសេវា training, app គ្រប់គ្រងករណីខូចខាតរហ័ស)។
- **ពង្រឹងកិច្ចសហការជាមួយក្រុមហ៊ុនធានារ៉ាប់រងដើម៖** ក្រុមហ៊ុនកម្ពុជារីគួរធ្វើសហការយ៉ាងជិតស្និទជាមួយក្រុមហ៊ុនដើមដើម្បីធានាថា អត្ថប្រយោជន៍របស់ខ្លួនត្រូវបានបញ្ជូនដល់អតិថិជនយ៉ាងច្បាស់ បង្កើតប្រព័ន្ធប្រតិបត្តិការរួម ដើម្បីអភិវឌ្ឍផលិតផល ឬយុទ្ធសាស្ត្រសេវាថ្មីៗ។

# ឯកសារយោង

១.គេហទំព័រផ្លូវការរបស់ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជារ៉េ":https://cambodiare.com.kh/
២. អនុក្រឹត្យលេខ២៧៥ស្តីពីធានារ៉ាប់រង *ស្តីពីកាតព្វកិច្ចរបស់អ្នកត្រូវបានធានារ៉ាប់រង* ឆ្នាំ២០២១ ទំព័រទី៨ ២៩ទំព័រ:
៣. អនុក្រឹត្យលេខ២៧៥ ឆ្នាំ២០២១ *ស្តីពីការធានារ៉ាប់រង* ទំព័រទី៣ ២៩ទំព័រ
៤. George E. Rejda and Rejda, George E. (2008). *Principle of Risk Management and Insurance* (12 ed.). United States of America: Pearson Education, Inc., Page 20. 644 Page.
៥. DDE, GJUS & T, Hisar. (2012). *Fundamentals of Insurance*. P.4 Retrieved 2025, August 12 from: https://share.google/JoC8Y4z89SWSWjfpr
៦. Linked in. Ecoinsoft Solution, (2023). *តើអ្វីទៅជាការធានារ៉ាប់រង ?* Retrieved 2025, August 15 from https://www.linkedin.com/pulse/តអវទជ-ករធនរបរង-ecoinsoft
៧. Britannica Money. Mark Richard Greene. (2025, June 28). *Insurance*. Retrieved 2025, August 15 from https://www.britannica.com/money/insurance
៨. Safetynet. (2025, June 29). តើអ្នកដឹងទេថាធានារ៉ាប់រងបន្តជាអ្វី ? Retrieved 2025, August 17 from https://share.google/O7zV8Y5CtSjkoc7pm
៩. Cambodia Re Blue venture: https://www.cambodiareblueventure.com.kh/about-us
១០. Investopedia. CAROLIN BANTON. (Updated 2025, February 28). *Reinsurance Definition, Types, and How It Works*. Retrieved 2025, August 17 from: https://www.investopedia.com/terms/r/reinsurance.asp
១១. Cambridge Dictionary. *Reinsurance*. Retrieved 2025, August 17 from https://dictionary.cambridge.org/dictionary/english/reinsurance
១២. Life & General Insurance, (2021). *Advantages of Reinsurance*. Retrieved 2025, August 17 from: https://www.lnginsurance.com/blog/advantages-of-reinsurance/
១៣. Share.google. Swiss Re. (2015). *The essential guide to reinsurance*. Page 1. 180 Page. Retrieved 2025, August 15 from https://share.google/P0FhpYJGys6qjjpsm

# ឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១៖** ការិយាល័យរបស់ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជារី"





**ឧបសម្ព័ន្ធទី២៖** សៀវភៅគំរូនៃការស្រាវជ្រាវ




**ឧបសម្ព័ន្ធទី៣៖** ផេករបស់ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា " កម្ពុជារី"

